# ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤

***◇***

## ១. សេចក្តីផ្តើម

**១.** ក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាព និងស្ថិរភាពនយោបាយរឹងមាំ ដែលនាំមកជូនប្រទេស និងប្រជាជនកម្ពុជាយើង ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា,** កម្ពុជាបានកសាង និងអភិវឌ្ឍប្រទេសឥតឈប់ឈរ ក្នុងរយៈពេលជាង ២ ទសវត្សរ៍កន្លងមក ។ ចាប់ពីទទួលបាននូវសុខសន្តិភាពពេញលេញ នៅចុងឆ្នាំ ១៩៩៨ រហូតដល់បច្ចុប្បន្ន, កម្ពុជាបានឆ្លងកាត់បរិវត្តកម្មដ៏ធំធេង ពីចំណុចបួយនៃផែនទីពិភពលោក ដែលប្រកបដោយកលិយុគ, សង្គ្រាមរ៉ាំរ៉ៃរាប់ទសវត្សរ៍, វាលពិឃាដ និងចម្ការមីន ដែលគេភ័យខ្លាចគ្រប់គ្នា ក្លាយជាប្រទេសដែលមានសុខសន្តិភាពពេញលេញ, មានសុវត្ថិភាព និងជាតំបន់ទេសចរណ៍លំដាប់សកលប្រកបដោយប្រជាប្រិយភាព និងស្វាមញ្ញញឹមដែលទទួលបានទេសចររាប់លាននាក់ក្នុងមួយឆ្នាំៗ ។ កម្ពុជាបានប្រែមុខមាត់ទាំងស្រុង ដោយទទួលបានការសាទរយ៉ាងខ្លាំងក្លា ទាំងពីសំណាក់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ, ដែលពីមុនធ្លាប់ជាប្រទេសទទួលរងការហ៊ុមព័ទ្ធ និងឯកា, ទាំងខាងនយោបាយ និងសេដ្ឋកិច្ច, ឥឡូវនេះ បានក្លាយជាប្រទេសដែលបានដឹកនាំសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ក្នុងឋានៈជាប្រធានប្តូរវេនប្រកបដោយជោគជ័យ ចំនួន ៣ លើក, និងបានក្លាយជាសមាជិកស្ថាបនិក នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដ៏ធំជាងគេបង្អស់ ក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ពោលគឺ កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) ។ កម្ពុជា, ដែលពីមុនធ្លាប់ជាប្រទេសគ្របដណ្តប់ទៅដោយភាពក្រីក្រ និងពោរពេញទៅដោយរូបភាពនៃប្រជាជនស្គមស្គាំង និងរងគ្រោះទុរភិក្ស, បានក្លាយទៅជាប្រទេសនាំចេញស្បៀង ហើយមានវឌ្ឍនភាពដ៏ល្អប្រសើរ ក្នុងការកាត់បន្ថយភាពក្រីក្រ និងបានឆ្លងកាត់ពីចំណាត់ថ្នាក់នៃប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប នៅឆ្នាំ ២០១៥ ។

**២.** ជាការពិត, មនុញ្ញផលនៃការអភិវឌ្ឍដែលយើងទាំងអស់គ្នាកំពុងតែក្រេបជញ្ជក់បច្ចុប្បន្ននេះ កើតចេញពីការដឹកនាំប្រកបដោយគតិបណ្ឌិត និងភាពឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, ដែលបាននាំមកនូវសមិទ្ធផលគួរជាទីមោទនៈ ពិសេស ជាបុព្វលក្ខខណ្ឌ និងជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍជាតិក្នុងរយៈពេលវែង នោះគឺ ÷ **១).** ការសម្រេច និងការរក្សាបាននូវសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម, សាមគ្គីភាព និងឯកភាពផ្ទៃក្នុងជាតិ, **២).** ការរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,



Telegram: t.me/economyfinance

៣). ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាព ដែលឆ្លើយតបបានទៅនឹងតម្រូវការអភិវឌ្ឍន៍ជាក់ស្តែង, ៤). ការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុឱ្យកាន់តែរីកចម្រើន ប្រកបដោយបរិយាបន្ន និងមានភាពធន់, ៥). ការលើកកម្ពស់ការបើកចំហពាណិជ្ជកម្មអន្តរជាតិដោយប្រកាន់ខ្ជាប់ "**ពហុភាគីនិយម**", និង ៦). ការពង្រឹង និងការពង្រីកការធ្វើសមាហរណកម្ម ព្រមទាំងការជំរុញបន្ថែមនូវការតភ្ជាប់ ក៏ដូចជាការធ្វើពិពិធកម្មពាណិជ្ជកម្ម និងការវិនិយោគ ក្នុងតំបន់ ។

៣. ឈរលើមូលដ្ឋានដ៏រឹងមាំនេះ, រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា ក៏បន្តសម្រេចបាននូវជោគជ័យយ៉ាងត្រចះត្រចង់ក្នុងការបម្រើប្រទេសជាតិ និងប្រជាជន ជាមួយសមិទ្ធផលជាច្រើនក្នុងការទ្រទ្រង់ដល់កិច្ចដំណើរការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចលើគ្រប់វិស័យ ក៏ដូចជាក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋកម្ពុជាដែលជាម្ចាស់ឆ្នោត ស្របតាមកម្មវិធីគោលនយោបាយដែលបានដាក់ចេញ ។ នៅដើមនីតិកាលទី ៦ នេះ, សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនខ្ពស់គួរឱ្យកត់សម្គាល់ រហូតដល់ ៧,៥% ក្នុងឆ្នាំ ២០១៨ និង ៧,១% ក្នុងឆ្នាំ ២០១៩ ដែលផ្លែផ្កានៃកំណើននេះ បានចូលរួមបង្កើតការងារជូនប្រជាពលរដ្ឋ, លើកកម្ពស់ជីវភាពរស់នៅ និងប្រាក់ចំណូល ព្រមទាំងកសាងមូលដ្ឋានគ្រឹះសង្គម-សេដ្ឋកិច្ចកម្ពុជា ឱ្យកាន់តែប្រសើរឡើងជាលំដាប់ ។ ប៉ុន្តែ, ចាប់ពីឆ្នាំ ២០២០ មក, កម្ពុជា ក៏ដូចជាប្រទេសផ្សេងទៀតទូទាំងពិភពលោក បានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីវិបត្តិជំងឺកូវីដ-១៩ ដែលជាវិបត្តិសុខភាពសកលដ៏កាចសាហាវបំផុត ។

៤. ទោះជាយ៉ាងនេះក្តី, កម្ពុជាបានយកឈ្នះលើសមរភូមិ នៃវិបត្តិជំងឺកូវីដ-១៩ នេះ ដែលឈានទៅរកការបើកប្រទេសឡើងវិញនាចុងឆ្នាំ ២០២១ និងជំរុញឱ្យសេដ្ឋកិច្ចកម្ពុជាវិលត្រឡប់ទៅរកវិថីនៃកំណើនឡើងវិញបានឆាប់រហ័ស តាមរយៈការដាក់ចេញជាបន្តបន្ទាប់ នូវវិធានការប្រកបដោយភាពម៉ឺងម៉ាត់, ទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ រួមមាន÷ (១). ការដាក់ចេញនូវយុទ្ធនាការជាតិចាក់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ-១៩ តាម **អភិក្រមផ្កាវីក** ដែលធ្វើឱ្យកម្ពុជាសម្រេចបាននូវ ***ភាពស៊ាំសហគមន៍*** គួបផ្សំនឹងការសម្របខ្លួនរបស់ប្រជាពលរដ្ឋ និងអាជីវកម្មតាមគន្លងប្រក្រតីភាពថ្មី, (២). ការដាក់ចេញនូវវិធានការអន្តរាគមន៍ទាំងលើវិជ្ជភាពសុខាភិបាល និងរដ្ឋបាល សំដៅកាត់បន្ថយឱ្យបានជាអតិបរមានៃការឆ្លងរីករាលដាល និង (៣). ការដាក់ចេញនូវវិធានការអន្តរាគមន៍ផ្នែកសង្គម-សេដ្ឋកិច្ច ក្នុងគោលដៅរក្សាលំនឹងជីវភាពប្រជាជន និងធានាស្ថិរភាពអាជីវកម្ម ក៏ដូចជាវិស័យហិរញ្ញវត្ថុ ជាពិសេស ប្រព័ន្ធធនាគារផងដែរ ។ បន្ថែមលើនេះ, រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រ និងគោលនយោបាយសំខាន់ៗ រួមមាន÷ "**ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣**", "**ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ឆ្នាំ ២០២១-២០៣៥**", "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២-២០២៧**", "**ក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា ២០២២-២០៣៥**", និង "**ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា**" ។ល។

៥. ក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ-១៩, រាជរដ្ឋាភិបាលបានប្រើប្រាស់ថវិកាប្រមាណ **១ ៣៥៥ លានដុល្លារអាមេរិក** ក្នុងឆ្នាំ ២០២១ និង **៦០១ លានដុល្លារអាមេរិក** ក្នុងឆ្នាំ ២០២២ សម្រាប់ការអនុវត្តវិធានការ



Telegram: t.me/economyfinance

អន្តរាគមន៍ ក្នុងការដោះស្រាយផលប៉ះពាល់ ទាំងផ្នែកសង្គម និងសេដ្ឋកិច្ច ដែលបណ្តាលមកពីវិបត្តិជំងឺកូវីដ-១៩ និងវិបត្តិសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ជាពិសេស លើកម្មវិធីប្រយុទ្ធ និងទប់ស្កាត់ជំងឺកូវីដ-១៩, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនកម្មករ-និយោជិត ដែលត្រូវបានព្យួរកិច្ចសន្យាការងារ, ការរៀបចំវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ, កម្មវិធីសាច់ប្រាក់ពលកម្ម ជាដើម ។ ក្នុងឆ្នាំ ២០២៣, រាជរដ្ឋាភិបាលបានបន្តត្រៀមបម្រុងថវិកាសម្រាប់អនុវត្តវិធានការអន្តរាគមន៍ក្នុងទំហំប្រមាណ **១ ០៣០ លានដុល្លារអាមេរិក** ទៀត ដោយផ្តោតបន្ថែមលើកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា, ហិរញ្ញប្បទានសម្រាប់សហគ្រាសធុនតូច និងមធ្យម, និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងបៃតង ជាដើម ។ ជារួម, វិធានការអន្តរាគមន៍ទាំងនេះ សបញ្ជាក់ឱ្យឃើញអំពីស្មារតីបុរេសកម្មរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រង និងទប់ទល់នឹងវិបត្តិដែលកំពុងកើតឡើងនានា ។ ទោះបីកម្ពុជាបានឆ្លងកាត់ព្យុះភ្លៀងជាបន្តបន្ទាប់ក៏ដោយ, រាជរដ្ឋាភិបាលមានសមត្ថភាពគ្រប់គ្រងស្ថានភាពបានល្អប្រសើរ និងអាចកសាងមូលដ្ឋានកំណើនសេដ្ឋកិច្ចបានឆាប់រហ័សឡើងវិញ ដោយការកាត់បន្ថយផលប៉ះពាល់សង្គម-សេដ្ឋកិច្ចឱ្យស្ថិតក្នុងកម្រិតទាប តាមរយៈការដាក់ចេញកញ្ចប់វិធានការគោល-នយោបាយជាច្រើន ។ ជាងនេះទៅទៀត, កម្ពុជាមានលទ្ធភាពធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ាន លើកទី ៤០ និង ៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ កាលពីខែ វិច្ឆិកា ឆ្នាំ ២០២២ កន្លងទៅ ប្រកបដោយភាពជោគជ័យ និងបានរៀបចំការប្រកួតកីឡាស៊ីហ្គេម លើកទី ៣២ (SEA Games) និង អាស៊ានប៉ារ៉ាហ្គេម លើកទី ១២ (ASEAN Para Games) យ៉ាងអធិកអធម និងប្រកបដោយមោទកភាពជាតិ ។

**៦.** ក្នុងក្របខណ្ឌសកល, សម្រាប់ឆ្នាំ ២០២២ និង ២០២៣, ពិភពលោកបាននិងកំពុងហ៊ុមព័ទ្ធដោយបញ្ហាប្រឈម និងភាពមិនប្រាកដប្រជាខ្ពស់ បើទោះបីជាមានភាពស្រាកស្រាន្តពីវិបត្តិជំងឺកូវីដ-១៩ ក្តី ។ សេដ្ឋកិច្ចសកលត្រូវបានប៉ាន់ស្មានក្នុងអត្រាកំណើនយឺត ពោលគឺ ៣,៤% សម្រាប់ឆ្នាំ ២០២២ និង ២,៨% សម្រាប់ឆ្នាំ ២០២៣ ដែលអត្រាកំណើននេះ ទាបជាងកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ ៣,៨% ក្នុងរយៈពេល ២០ ឆ្នាំចុងក្រោយ ដោយសារការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ដែលបានបង្កឱ្យមានបច្ច័យអវិជ្ជមានមកលើកំណើនសេដ្ឋកិច្ច, ការកើនឡើងសម្ពាធអតិផរណា, វិបត្តិថាមពល និងការបន្តកើនឡើងអត្រាការប្រាក់ ដែលដាក់សម្ពាធដល់បណ្តាប្រទេសអភិវឌ្ឍន៍ និងជាដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា រួមមាន សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ។

**៧.** សម្រាប់ឆ្នាំ ២០២៤, កំណើនសេដ្ឋកិច្ចសកលត្រូវបានព្យាករថានឹងបន្តងើបឡើងក្នុងរង្វង់ ៣,០% ដោយ-សារការរំពឹងទុកនូវភាពស្រាកស្រាន្តបន្តិចម្តងៗ និងការបន្សាំជាបណ្តើរៗ ជាមួយនឹងឥទ្ធិពលសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងសម្ពាធអតិផរណា ដែលនឹងធ្វើឱ្យថ្លៃទំនិញសកលមានការថមថយ ស្របនឹងការចាកចេញពីវិបត្តិជំងឺកូវីដ-១៩ ។ ប៉ុន្តែ, អត្រាកំណើននេះ គឺនៅទាបជាងកំណើនសក្តានុពលនៅឡើយ, ហើយសេដ្ឋកិច្ចសកលបន្តប្រឈមនឹងហានិភ័យចម្បងៗផ្សេងទៀត រួមមាន៖ ការបន្តកើនឡើងនូវបំណុលសាធារណៈជាសកល, សម្ពាធក្នុងវិស័យហិរញ្ញវត្ថុ និងអតិ-ផរណា, ផលប៉ះពាល់ជាអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ, ភាពតានតឹងនៃភូមិសាស្ត្រនយោបាយរវាងប្រទេសមហាអំណាចកាន់តែមានលក្ខណៈស្រួចស្រាល់, សង្គ្រាមពាណិជ្ជកម្ម និងបច្ចេកវិទ្យា, និងចរន្តគាំពារនិយម ដែលកំពុង



Telegram: t.me/economyfinance

ធ្វើឱ្យសណ្តាប់ធ្នាប់សកលកាន់តែស្មុគស្មាញ និងបង្កើននូវអស្ថិរភាពដល់ប្រព័ន្ធពាណិជ្ជកម្មសកល ។ ជាលទ្ធផល, និន្នាការទាំងនេះត្រូវបានវាយតម្លៃថានឹងពន្លឿនការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ចសកល ។ ដោយឡែក, និន្នាការវិជ្ជមានមួយចំនួន ក៏អាចផ្តល់កាលានុវត្តភាព សម្រាប់ការរួមចំណែកជំរុញចលនការសេដ្ឋកិច្ចសកលឱ្យងើបឡើងវិញលឿន ដូចជា ការចាប់យកប្រយោជន៍ពីការវិវត្តយ៉ាងឆាប់រហ័សនៃបរិវត្តកម្មឌីជីថល និងឌីជីថលូបនីយកម្មក្នុងវិស័យសង្គម និងវិស័យសេដ្ឋកិច្ច, ការជំរុញការធ្វើអន្តរកាលថាមពល (**Energy Transition**), ការបង្កើនវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធបៃតង និងឌីជីថល, ការពង្រឹងប្រព័ន្ធគាំពារសង្គម, ការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងការបង្កើនហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍ ជាដើម ។

**៨.** ដោយជាប្រទេសដែលមានសេដ្ឋកិច្ចបើកចំហកម្រិតខ្ពស់, កម្ពុជាបាននិងកំពុងទទួលរងនូវឥទ្ធិពលពីការប្រែប្រួលយ៉ាងឆាប់រហ័សនូវជវភាព និងនិម្នាបនកម្មសង្គម-សេដ្ឋកិច្ចតំបន់ និងសកល ដែលកំពុងនាំមកនូវនិន្នាការថ្មីៗ រួមមាន ÷

**(១).** ប្រទេសអភិវឌ្ឍន៍ធំៗ កំពុងរៀបចំឡើងវិញជារចនាសម្ព័ន្ធនូវខ្សែច្រវាក់ផ្គត់ផ្គង់ និងផលិតកម្មតំបន់ និងសកល (**Reconfiguration of global and regional supply chains and production chains**) តាមរយៈការធ្វើពិពិធកម្មមូលដ្ឋានផលិតកម្ម ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនូវកិច្ចសហការជាប្លុក ដោយគិតគូរ និងរៀបចំបណ្តុំឧស្សាហកម្មផលិតកម្ម តាមតំបន់ជាយុទ្ធសាស្ត្រ ដែលផ្តោតសំខាន់លើកត្តាភូមិសាស្ត្រនយោបាយ ។

**(២).** បណ្តារដ្ឋាភិបាលលើសកលលោក ទាំងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍ បាននិងកំពុងបង្កើនការយកចិត្តទុកដាក់ ក្នុងការពង្រឹងសមត្ថភាពផលិតកម្មក្នុងស្រុក ជាពិសេសលើទំនិញយុទ្ធសាស្ត្រ សំដៅបញ្ចៀសនូវហានិភ័យនានា និងកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានពីវិបត្តិដែលអាចកើតឡើងជាយថាហេតុនាពេលអនាគត ដូចជា អសន្តិសុខស្បៀង និងអសន្តិសុខថាមពល ជាដើម តាមរយៈការបង្កើនធនធាន និងកែសម្រួលគោលនយោបាយ (**Policy Calibration**) ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍ ។ ប្រទេសជាច្រើនកំពុងគិតគូរជាយុទ្ធសាស្ត្រ និងបង្កើនកិច្ចខិតខំប្រឹងប្រែងតាមលទ្ធភាព លើការអភិវឌ្ឍដោយពឹងអាស្រ័យលើខ្លួនឯងកាន់តែខ្លាំង ។

**(៣).** ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ច កំពុងកាត់បន្ថយនូវការចូលរួមក្នុងចរន្តសកលភាវូបនីយកម្ម ស្របជាមួយនឹងការកើនឡើងនៃនិន្នាការពហុប៉ូល និងការបែងចែកប្លុកសេដ្ឋកិច្ច និងពាណិជ្ជកម្ម ។ និន្នាការទាំងនេះ មិនត្រឹមតែអាចកាត់បន្ថយវិហ្វរពលកម្មឆ្លងដែន, ទំនិញ, វិនិយោគ, ការចែករំលែកនូវបច្ចេកវិទ្យាថ្មីៗជាសកលសម្រាប់ជំរុញការអភិវឌ្ឍប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងធ្វើឱ្យផលិតភាពសេដ្ឋកិច្ច ក៏ដូចជា ប្រសិទ្ធភាពប្រព័ន្ធទូទាត់អន្តរជាតិ និងសហថាមភាពនៃកិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍ ធ្លាក់ចុះផងដែរ ជាពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍ ។

**(៤).** រដ្ឋាភិបាលគ្រប់បណ្តាប្រទេស នៅតែផ្តោតសំខាន់ជាយុទ្ធសាស្ត្រលើការអភិវឌ្ឍវិស័យសង្គមកិច្ច, សេដ្ឋកិច្ច និងបរិស្ថាន ដើម្បីពង្រឹងភាពធន់ និងរឹងមាំនៃសង្គម-សេដ្ឋកិច្ចរបស់ខ្លួនក្នុងរយៈពេលវែង ។ បណ្តាប្រទេស

ជាច្រើនកំពុងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ដើម្បីជំរុញការចាប់យកប្រយោជន៍ជាអតិបរមា ពីបរិវត្តកម្មឌីជីថល និងឌីជីថលូបនីយកម្ម, និងការបង្កើនវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធបៃតង និងឌីជីថល ជាដើម ។

**(៥).** ក្រោយវិបត្តិជំងឺកូវីដ-១៩, កង្វះហិរញ្ញប្បទាន និងភាពមានកម្រិតនៃកិច្ចសហការប្រតិបត្តិការអន្តរជាតិ បានក្លាយជាបញ្ហាប្រឈមមួយដ៏ចម្បងសម្រាប់ប្រទេសកំពុងអភិវឌ្ឍ ក្នុងការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព **(SDGs)** ។ ការណ៍នេះបានធ្វើឱ្យបណ្តាប្រទេសកំពុងអភិវឌ្ឍ បង្កើនការយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រឹងសមត្ថភាព និងរៀបចំគោលនយោបាយនានា ដូចជា យុទ្ធសាស្ត្រហិរញ្ញប្បទានគ្រប់ជ្រុងជ្រោយ ដើម្បីទាញយកប្រយោជន៍ពីការកើនឡើងនូវហិរញ្ញប្បទានសហប្រតិបត្តិការសកលសម្រាប់ការអភិវឌ្ឍ ដូចជា មូលនិធិអាកាសធាតុបៃតង **(Green Climate Fund)** និងមូលនិធិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព **(SDGs fund)** ជាដើម សំដៅសម្រេចឱ្យបាននូវការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយភាពធន់, បរិយាបន្ន និងចីរភាព ។

**៩.** ការប្រែប្រួលបរិបទតំបន់ និងសកលនេះ នឹងអាចនាំមកនូវបច្ច័យអវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជា ប៉ុន្តែក៏អាចផ្តល់កាលានុវត្តភាពផងដែរ ក្នុងការជំរុញការកែទម្រង់ផ្ទៃក្នុងឱ្យកាន់តែស៊ីជម្រៅ និងមុតស្រួចជាងមុនបន្ថែមទៀត ក្នុងគោលដៅពង្រឹងភាពធន់រឹងមាំនៃសង្គម-សេដ្ឋកិច្ច ព្រមទាំងពន្លឿនការធ្វើពិពិធកម្មសេដ្ឋកិច្ច និងលើកកម្ពស់ភាពប្រកួតប្រជែង ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវការផ្សារភ្ជាប់សេដ្ឋកិច្ចកម្ពុជាទៅនឹងច្រវាក់ផ្គត់ផ្គង់តំបន់ និងសកល ។ ផ្អែកលើតថភាពនេះ, ការរៀបចំគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ត្រូវមានចរិតតម្រង់ឱ្យចំគោលដៅជាអាទិភាព (Targeted fiscal policy) ដោយម្ខាង តម្រង់ឆ្ពោះទៅរកការកាត់បន្ថយសម្ពាធអតិផរណា សំដៅរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងម្ខាងទៀត ជំរុញការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ចឱ្យបានឆាប់ ។ ដោយឡែក, ការកសាងឡើងវិញនូវទ្រនាប់សារពើពន្ធ (Fiscal buffers) មានសារៈសំខាន់ណាស់ក្នុងការសម្រេចបាននូវស្ថិរភាពហិរញ្ញវត្ថុសាធារណៈ ដោយចាប់ផ្តើមបន្ថយកញ្ចប់អន្តរាគមន៍សម្រាប់វិបត្តិជំងឺកូវីដ-១៩ ដោយសន្សឹមៗ ដើម្បីជៀសវាងនូវការកើតឡើងឧបសគ្គថ្មីបន្ថែមទៀត ។ យ៉ាងណាមិញ, ដោយសារលំហថវិកាមានការរួមតូច ខណៈធនធានកាន់តែមានកម្រិត, រដ្ឋាភិបាលថ្លឹងថ្លែង (Policy trade-offs) យ៉ាងហ្មត់ចត់នូវរវាងគោលនយោបាយជាអាទិភាពចំពោះមុខ ជាពិសេស ការបង្កើនចំណាយលើការពង្រឹងភាពធន់រឹងមាំសង្គម (Social resilience) និងការតម្រង់ចំណាយលើវិស័យដែលមានសក្តានុពលខ្ពស់ ដែលអាចទ្រទ្រង់ និងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ដូចជា ការបង្កើនចំណាយសម្រាប់តម្រូវការហេដ្ឋារចនាសម្ព័ន្ធ និងវិស័យជំរុញកំណើនថ្មីៗ ជាដើម ។

**១០.** សម្រាប់ឆ្នាំ ២០២៤ ដែលជាឆ្នាំដំបូងនៃរាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងបន្តដាក់ចេញនូវយុទ្ធសាស្ត្រ និងគោលនយោបាយគន្លឹះៗ ដើម្បីធានាឱ្យបាននូវ **"កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព និងចីរភាព"** សម្រាប់បន្តអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ដោយឈរលើគោលការណ៍ **"រក្សាសមិទ្ធផលចាស់ បង្កើតសមិទ្ធផលថ្មី"** និង **"គិតគូរជាសកល និងអនុវត្តតាមបរិការណ៍ក្នុងប្រទេស (Think Globally and Act Locally)"** ក្នុងគោលដៅ

ឈានទៅសម្រេចឱ្យបាននូវចក្ខុវិស័យ ក្នុងការប្រែក្លាយកម្ពុជាឱ្យទៅជា **ប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់** នៅឆ្នាំ ២០៣០ និងក្លាយជា **ប្រទេសមានចំណូលខ្ពស់** នៅឆ្នាំ ២០៥០, និងសំដៅសម្រេចឱ្យបាននូវគោលបំណង ២ គឺ÷ **(១).** ការកសាងកម្ពុជា ជារដ្ឋឯករាជ្យ, មានអធិបតេយ្យភាពរឹងមាំ, មានភាពជាម្ចាស់ក្នុងការអភិវឌ្ឍ, មានស្ថិរភាពនយោបាយ និងជានីតិរដ្ឋពេញលេញ ប្រកបដោយកិត្យានុភាពខ្ពង់ខ្ពស់លើឆាកអន្តរជាតិ, និង **(២).** ការលើកកម្ពស់ជីវភាពប្រជាជនកម្ពុជាឱ្យទៅជាប្រជាជនដែលមានចំណូលខ្ពស់, មានចំណេះដឹង និងមានការរស់នៅ ប្រកបដោយភាពថ្លៃថ្នូរ និងភាពស៊ីវិល័យ ។

## ២. សមិទ្ធផលសេដ្ឋកិច្ចឆ្នាំ ២០២២

**១១.** ក្នុងឆ្នាំ ២០២២, សេដ្ឋកិច្ចសកលនៅបន្តរក្សាបានកំណើនវិជ្ជមាន ក្នុងអត្រាប្រមាណ ៣,៤% ។ យ៉ាងណាមិញ, សន្ទុះកំណើនមានការថមថយធៀបនឹង ឆ្នាំ ២០២១ ដោយសារការផ្ទុះឡើង និងបន្តអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ដែលធ្វើឱ្យមានការលេចចេញនូវនិន្នាការអវិជ្ជមានមួយចំនួន រួមមាន÷ ការកើនឡើងសម្ពាធអតិផរណាលឿន និងយ៉ាងគំហុក, និងការរឹតបន្តឹងយូរជាងការរំពឹងទុកនៃគោលនយោបាយរូបិយវត្ថុ, ព្រមទាំងការបន្តដាក់ចេញនូវគោលនយោបាយគ្មានកូវីដ (Zero Covid Policy) របស់ប្រទេសចិន ។

**១២.** បើទោះបីសេដ្ឋកិច្ចសកល និងតំបន់ប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់ក្តី, សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២២ បានបន្តងើបឡើងវិញលឿនក្នុងអត្រាកំណើន ៥,២% ពីកំណើន ៣,០% ក្នុងឆ្នាំ ២០២១ ដែលទ្រទ្រង់ដោយកំណើនរឹងមាំនៃវិស័យឧស្សាហកម្ម (កាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ) និងការងើបឡើងវិញលឿនជាងការរំពឹងទុកនៃវិស័យទេសចរណ៍ និងសេវាកម្មគាំទ្រ ដោយសារភាពល្អប្រសើរនៃតម្រូវការខាងក្រៅ និងការវិលត្រឡប់ទៅរកប្រក្រតីភាពឡើងវិញនៃការធ្វើដំណើរក្នុងស្រុក, តំបន់ និងសកល ។ វិស័យឧស្សាហកម្មបន្តសម្រេចបានកំណើនល្អប្រសើរក្នុងអត្រា ៨,៣% ទ្រទ្រង់ដោយកំណើនរឹងមាំនៃអនុវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ខណៈដែលអនុវិស័យសំណង់នៅបន្តមានកំណើនទាប ។ វិស័យសេវាកម្មងើបឡើងវិញក្នុងអត្រាកំណើន ៤,៦% ទ្រទ្រង់មួយផ្នែកធំដោយការងើបឡើងវិញលឿនជាងការរំពឹងទុកនៃអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន (វិស័យទេសចរណ៍) ។ វិស័យកសិកម្មនៅបន្តរក្សាបានកំណើនវិជ្ជមានក្នុងអត្រា ០,៧% បន្តគាំទ្រដោយអនុវិស័យចិញ្ចឹមសត្វ, អនុវិស័យដំណាំ (ដំឡូងមី និងពោត) និងការងើបឡើងវិញនៃអនុវិស័យនេសាទ ។ កំណើនទាបនៃវិស័យនេះ មួយផ្នែកធំបណ្តាលមកពីការកើនឡើងថ្លៃធាតុចូលកសិកម្ម និងការអនុវត្តគោលនយោបាយគ្មានកូវីដ-១៩ របស់ចិន ។

**១៣.** ទន្ទឹមនេះ, ស្ថានភាពហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា សម្រេចបាននូវលទ្ធផលគួរឱ្យកត់សម្គាល់ ។ ជាក់ស្តែង, ការប្រមូលចំណូលក្នុងស្រុកសម្រាប់ឆ្នាំ ២០២២ (តួលេខបណ្តោះអាសន្ន) សម្រេចបានប្រមាណ ២៣,០៩% នៃ ផសស ពោលគឺ មានការកើនឡើង ប្រមាណ ២,៤ ពិន្ទុភាគរយ នៃផសស ធៀបនឹងលទ្ធផលឆ្នាំ ២០២១ ដោយសារការងើបឡើងវិញលឿននៃសកម្មភាពសេដ្ឋកិច្ច ទាំងផលិតកម្មក្នុងស្រុក និងពាណិជ្ជកម្មអន្តរជាតិ, ព្រមទាំងការពង្រឹងអនុលោមភាពអ្នកជាប់ពន្ធ និងការបង្ក្រាបការគេចវេសកាតព្វកិច្ចពន្ធ ក៏ដូចជាការធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធសារពើពន្ធ ។ ជាមួយនឹងលទ្ធផលប្រមូលចំណូលល្អប្រសើរនេះ, ការអនុវត្តចំណាយក្នុងឆ្នាំ ២០២២


Telegram: t.me/economyfinance

មានទំហំប្រមាណ ២៦,៨៤% នៃ ផសស (តួលេខបណ្ដោះអាសន្ន) សមាមាត្រនឹង ៩៣,៥% នៃច្បាប់ថវិកា ពោលគឺមានការធ្លាក់ចុះប្រមាណ -៥,០% ធៀបនឹងឆ្នាំ ២០២១ ជាមួយនឹងភាពធូរស្រាលនៃសម្ពាធថវិកាក្នុងការដោះស្រាយបញ្ហាសេសសល់ពីវិបត្តិកូវីដ-១៩ ។ ក្នុងនោះ, រាជរដ្ឋាភិបាលបានបន្តរក្សាកម្រិតប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ព្រមទាំងធ្វើវិចារណកម្មលើមុខចំណាយលែងចាំបាច់នានា ដើម្បីសន្សំថវិកាសម្រាប់ទប់ទល់នឹងការរាតត្បាតនៃជំងឺកូវីដ-១៩ និងបង្វែរថវិកាសម្រាប់ជួយទ្រទ្រង់ការដាក់ចេញនូវកញ្ចប់ថវិកាអន្តរាគមន៍ក្នុងទំហំ ៦០១ លានដុល្លារអាមេរិក ។ ជាលទ្ធផល, ឱនភាពថវិកាក្នុងឆ្នាំ ២០២២ មានភាពល្អប្រសើរជាងការរំពឹងទុក ដែលស្ថិតក្នុងកម្រិត -៣,៧៤% នៃផសស ធៀបនឹងការគ្រោងក្នុងច្បាប់ថវិកា -៧,៥៣% នៃផសស ។

## ៣. ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

**១៤.** សេដ្ឋកិច្ចសកលត្រូវបានព្យាករថាមានកំណើនយឺតក្នុងអត្រា ២,៨% សម្រាប់ឆ្នាំ ២០២៣ និង ៣,០% សម្រាប់ឆ្នាំ ២០២៤ ដែលជាកំណើនមួយទាបជាងអត្រាកំណើនមធ្យមប្រចាំឆ្នាំ ក្នុងរយៈពេល ២០ ឆ្នាំចុងក្រោយ ។ កំណើនយឺតនេះ ដោយសារការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ សំដៅឆ្លើយតបទៅនឹងកម្រិតខ្ពស់នៃអតិផរណា ធៀបនឹងអត្រាគោលដៅ ជាពិសេស នៅបណ្ដាប្រទេសអភិវឌ្ឍន៍ និងផលប៉ះពាល់ពីសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន មកលើការផ្គត់ផ្គង់ និងថ្លៃថាមពល ។ សម្រាប់ឆ្នាំ ២០២៤, កំណើនសេដ្ឋកិច្ចសកលនឹងបន្តងើបឡើងវិញក្រោមការរំពឹងទុកនូវការថមថយនៃឥទ្ធិពលអវិជ្ជមានពីសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងការគ្រប់គ្រងបាននូវអតិផរណាជាសន្សឹមៗ ។ ទោះជាយ៉ាងនេះក្ដី, ទស្សនវិស័យសេដ្ឋកិច្ចសកល បាននិងកំពុងហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាមួយចំនួន ដែលនៅតែអាចបន្តឃ្មីមកលើការខិតខំប្រឹងប្រែងស្ដារសេដ្ឋកិច្ចឡើងវិញរបស់ប្រទេសនានាលើសកលលោក រួមមាន÷ **(១).** ការបន្តអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ដែលបង្កជាបច្ច័យអវិជ្ជមានមកលើថ្លៃថាមពលលើទីផ្សារអន្តរជាតិ, **(២).** ការកើនឡើងនូវភាពតានតឹងផ្នែកហិរញ្ញវត្ថុ, **(៣).** កម្រិតខ្ពស់នៃអតិផរណា, **(៤).** ការបែងចែកភូមិសាស្ត្រនយោបាយ និង **(៥).** ការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ជាដើម ។ ក្នុងបរិបទនេះ, ទិសដៅគោលនយោបាយជាសកល ផ្ដោតសំខាន់ទៅលើការកាត់បន្ថយសម្ពាធអតិផរណា, ការទប់ស្កាត់ការផ្ទុះឡើងវិញនៃជំងឺកូវីដ-១៩, ការធានាឱ្យបាននូវស្ថិរភាពហិរញ្ញវត្ថុ, ការធានានូវចីរភាពបំណុល និងការកសាងលំហថវិកាឡើងវិញ, ការគាំទ្រដល់ក្រុមជនងាយរងគ្រោះ, ការពង្រឹងខ្សែច្រវាក់ផ្គត់ផ្គង់ និងការជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិ ។

**១៥. ក្នុងឆ្នាំ ២០២៣, សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានឡើងវិញថានឹងសម្រេចបានកំណើនក្នុងអត្រា ៥,៦%**, ប៉ុន្តែ អនុវិស័យគាំទ្រកំណើនមានការប្រែប្រួលធៀបនឹងការរំពឹងទុកកាលពីដើមឆ្នាំ ។ អនុវិស័យកាត់ដេរត្រូវបានប៉ាន់ស្មានថាមានកំណើនថមថយខ្លាំង ខណៈដែលអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន និងសេវាកម្មគាំទ្រផ្សេងទៀត ត្រូវបានវាយតម្លៃឡើងវិញថានឹងសម្រេចបានកំណើនខ្ពស់ជាងការរំពឹងទុក ។ ជាក់ស្ដែង, ការថមថយនៃអនុវិស័យកាត់ដេរនេះ បណ្ដាលមកពីការធ្លាក់ចុះតម្រូវការជាសកល ជាពិសេស ពីប្រទេសដៃគូពាណិជ្ជកម្ម ដូចជា សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប, ខណៈដែលអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ នៅបន្តរក្សាកំណើនរឹងមាំ ដូចការរំពឹងទុកដោយសារសក្ដានុពលខ្ពស់នៃសកម្មភាពផលិតកម្មបម្រើឱ្យការនាំចេញមួយចំនួន រួមមាន÷ គ្រឿងបង្គុំសូឡា, កង់ និង



Telegram: t.me/economyfinance

សំបកកង់, ព្រមទាំងផលិតកម្មបម្រើឱ្យតម្រូវការក្នុងស្រុក ជាពិសេស ផលិតកម្មចំណីអាហារ និងភេសជ្ជៈ និងឧស្សាហកម្មដំឡើងយានយន្ត ជាដើម ។ អនុវិស័យសំណង់ និងអចលនទ្រព្យ នៅបន្តកំណើនវិជ្ជមានទាប ដោយសារការបន្តធ្លាក់ចុះសកម្មភាពសំណង់ និងចរន្តទិញ-លក់លំនៅឋានថ្លៃខ្ពស់ ប៉ុន្តែត្រូវបានប៉ះប៉ូវដោយកំណើនសកម្មភាពសំណង់ និងចរន្តទិញ-លក់លំនៅឋានថ្លៃទាប ក៏ដូចជាសំណង់ក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម ។ វិស័យកសិកម្មនៅបន្តរក្សាកំណើនវិជ្ជមាន ប៉ុន្តែមានការកើនឡើងទាបជាងការរំពឹងទុក ដោយសារការថមថយនៃអនុវិស័យដំណាំ ជាពិសេសស្រូវវស្សា បណ្តាលមកពីកត្តាអាកាសធាតុ និងការថមថយនៃអនុវិស័យចិញ្ចឹមសត្វ ដូចជា ផលិតកម្មជ្រូក និងភាពមានកម្រិតនៃសមត្ថភាពក្នុងការប្រកួតប្រជែងជាមួយនឹងការនាំចូលពីក្រៅប្រទេស ។ យ៉ាងណាមិញ, កំណើនក្នុងឆ្នាំ ២០២៣ ត្រូវបានជំរុញដោយការកើនឡើងខ្ពស់ជាងការរំពឹងទុកនៃអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន (វិស័យទេសចរណ៍) គាំទ្រដោយការកាត់បន្ថយរបាំងធ្វើដំណើរជាអតិបរមាក្នុងកម្រិតសកល និងអនុវិស័យគាំទ្រផ្សេងទៀត ដូចជា អនុវិស័យដឹកជញ្ជូន និងអនុវិស័យលក់ដុំ-រាយ ជាដើម ។ បន្ថែមលើនេះ, ការប្រារព្ធកីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេមក្នុងឆ្នាំនេះ ដែលជាព្រឹត្តិការណ៍ប្រវត្តិសាស្រ្តមួយរបស់កម្ពុជា នឹងទាក់ទាញទេសចរអន្តរជាតិ មកកម្ពុជាបន្ថែមទៀត ។ ការបន្តកើនឡើងនៃទេសចរអន្តរជាតិនេះ និងការបន្តអនុវត្តវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល ជាពិសេស ការដាក់ចេញនូវកញ្ចប់អន្តរាគមន៍សម្រាប់គ្រួសារងាយរងហានិភ័យ ក៏បង្កើតផលជះវិជ្ជមានទៅលើអនុវិស័យផ្សេងទៀតផងដែរ ជាពិសេស សកម្មភាពប្រើប្រាស់ក្នុងស្រុក ក៏ដូចជាសេវាកម្មគាំទ្រផ្សេងទៀត ។ សម្រាប់ឆ្នាំ ២០២៤, សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងសម្រេចបានអត្រាកំណើនក្នុងរង្វង់ ៦,៦% ដោយសារការរំពឹងទុកការត្រឡប់ទៅរកភាពល្អប្រសើរឡើងវិញនៃតម្រូវការខាងក្រៅ និងការងើបឡើងវិញនៃទំនុកចិត្តវិនិយោគ និងពាណិជ្ជកម្ម ស្របពេលដែលសកម្មភាពធុរកិច្ចក្នុងស្រុក នៅបន្តរក្សាបាននូវនិន្នាការកំណើនល្អជាវិជ្ជមាន ។ ទន្ទឹមនេះ, ការអនុវត្ត **"ក្របខណ្ឌយុទ្ធសាស្រ្ត និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣"** ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក បាននិងកំពុងជួយស្តារវិស័យចន្លល់កំណើនដែលមានស្រាប់ និងជំរុញការអភិវឌ្ឍដល់វិស័យសក្តានុពលថ្មីៗ រួមមាន÷ ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម, អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ព្រមទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងបៃតង ជាពិសេស រួមចំណែកពង្រឹងនូវមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍ (Foundation for Development) សំដៅបន្តធ្វើការកែទម្រង់ឱ្យកាន់តែស៊ីជម្រៅ ដើម្បីលើកកម្ពស់ភាពធន់នៃសង្គម-សេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេលមធ្យម និងវែង ។ ផ្អែកលើមូលដ្ឋានខាងលើ, សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២៣ និង ២០២៤ ត្រូវបានព្យាករដូចខាងក្រោម ÷

**១៦. វិស័យកសិកម្ម** ត្រូវបានព្យាករថានឹងសម្រេចបានកំណើនក្នុងរង្វង់ ០,៩% ក្នុងឆ្នាំ ២០២៣ និង ១,១% ក្នុងឆ្នាំ ២០២៤ គាំទ្រដោយកំណើននៃអនុវិស័យដំណាំ និងអនុវិស័យចិញ្ចឹមសត្វ ស្របពេលដែលអនុវិស័យនេសាទរំពឹងថានឹងបន្តងើបឡើងវិញសន្សឹមៗ ។ ទន្ទឹមនេះ, ការបន្តអនុវត្ត**គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០២១-២០៣០** និងការដាក់ពង្រាយអ្នកជំនាញកសិកម្ម នៅគ្រប់ឃុំទូទាំងប្រទេស ដើម្បីជួយប្រជាកសិករ នឹងជួយជំរុញកំណើនជារួម តាមរយៈការធ្វើទំនើបកម្មកសិកម្មកម្ពុជាឱ្យកាន់តែមានភាពប្រកួតប្រជែង, បរិយាបន្ន និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ។

**១៧. អនុវិស័យដំណាំ** ត្រូវបានព្យាករថានឹងមានកំណើន ១,៥% ក្នុងឆ្នាំ ២០២៣ និង ១,៧% ក្នុងឆ្នាំ ២០២៤ ដោយសារការរំពឹងទុកនូវកំណើននៃផលិតកម្មសម្រាប់ប្រើប្រាស់ក្នុងស្រុក និងបម្រើការនាំចេញ ជាពិសេស គាំទ្រដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីផ្សេងៗ ដូចជា "**កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន**", "**កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ**" និង "**កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់**" ជាដើម គួបផ្សំនឹងការបង្កើនការវិនិយោគរបស់រាជរដ្ឋាភិបាល តាមរយៈការបន្តផ្តល់ការលើកទឹកចិត្តផ្នែកពន្ធសម្រាប់ការនាំចូលវត្ថុធាតុដើមកសិកម្ម និងការផ្តល់ហិរញ្ញប្បទានក្នុងការជំរុញផលិតកម្មក្នុងស្រុក ។

**១៨. អនុវិស័យចិញ្ចឹមសត្វ** ត្រូវបានព្យាករថាសម្រេចបានកំណើនក្នុងរង្វង់ ០,៨% ក្នុងឆ្នាំ ២០២៣ និង ០,៩% ក្នុងឆ្នាំ ២០២៤ គាំទ្រដោយការរំពឹងទុកការបន្តកើនឡើងនៃផលិតកម្មលក្ខណៈពាណិជ្ជកម្ម ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងស្រុក គួបផ្សំនឹងវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល និងការអនុវត្តគម្រោងរបស់ដៃគូអភិវឌ្ឍន៍នានា ។ ទោះជាយ៉ាងនេះក្តី, ការចិញ្ចឹមសត្វលក្ខណៈគ្រួសារអាចប្រឈមនឹងការថមថយ ដោយសារថ្លៃធាតុចូលបន្តមានកម្រិតខ្ពស់ ស្របពេលដែលការនាំចូលសាច់បង្កកក៏បានដាក់សម្ពាធបន្ថែមមកលើថ្លៃសាច់ក្នុងទីផ្សារ ។

**១៩. អនុវិស័យនេសាទ** ត្រូវបានព្យាករថាបន្តងើបឡើងវិញសន្សឹមៗក្នុងរង្វង់ ០,៤% ក្នុងឆ្នាំ ២០២៣ និង ០,៦% ក្នុងឆ្នាំ ២០២៤ ក្រោមការរំពឹងទុកនូវកំណើនល្អប្រសើរនៃផលចាប់ទឹកសាប ដោយការដាក់ចេញនូវគោលនយោបាយបង្ក្រាបបទល្មើសនេសាទ គួបផ្សំនឹងការងើបឡើងវិញជាបណ្តើរៗនៃផលិតកម្មវារីវប្បកម្ម ដោយសារវារីវប្បករមួយចំនួនចាប់ផ្តើមផ្លាស់ប្តូរទៅចិញ្ចឹមប្រភេទត្រីដែលមានការប្រកួតប្រជែងតិច ព្រមទាំងការជួយជ្រោមជ្រែងពីរាជរដ្ឋាភិបាល តាមរយៈការដោះស្រាយបញ្ហាប្រឈមជារចនាសម្ព័ន្ធ, ការគាំទ្រផ្នែកហិរញ្ញប្បទាន, ការផ្សព្វផ្សាយបច្ចេកទេស និងការប្រើប្រាស់ពូជត្រីប្រកបដោយប្រសិទ្ធភាព និងគុណភាពខ្ពស់ ។

**២០.** ទោះជាយ៉ាងនេះក្តី, វិស័យកសិកម្ម នៅបន្តជួបប្រទះបញ្ហាប្រឈមជារចនាសម្ព័ន្ធ រួមមាន÷ កំណើនទាបនៃផលិតភាពដី និងផលិតភាពពលកម្ម, ថ្លៃដើមផលិតកម្មខ្ពស់, ភាពមានកម្រិតនៃហេដ្ឋារចនាសម្ព័ន្ធ និងសេវាគាំទ្រ, ភាពទន់ខ្សោយនៃការធ្វើពាណិជ្ជូបនីយកម្ម និងពិពិធកម្មកសិកម្ម, និងកង្វះការវិនិយោគលើការកែច្នៃផលិតផលកសិកម្ម ដើម្បីទាញយកតម្លៃបន្ថែមឱ្យអស់ពីសក្តានុពល ។ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនេះ និងជំរុញវិស័យកសិកម្មឱ្យមានកំណើនកាន់តែល្អប្រសើរ សំដៅគាំទ្រដល់សេដ្ឋកិច្ចជាតិ ព្រមទាំងលើកកម្ពស់សន្តិសុខស្បៀង, រាជរដ្ឋាភិបាលបាននិងកំពុងបន្តអនុវត្តវិធានការគោលនយោបាយ ដូចជា÷ ១). ការវិនិយោគលើផលិតកម្មពូជសុទ្ធដែលមានគុណភាពល្អ, ២). ការវិនិយោគលើប្រព័ន្ធស្រោចស្រពខ្នាតតូច និងមធ្យម ក្នុងតំបន់ដែលមានសក្តានុពលស្រូវក្រអូប និងដំណាំឧស្សាហកម្មផ្សេងទៀត, ៣). ការលើកកម្ពស់ការកែច្នៃធាតុចូលកសិកម្ម ដូចជា ចំណីសត្វ ជីគីមី និងថ្នាំកសិកម្មក្នុងស្រុក, ៤). ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ជាពិសេស ផ្សារបោះដុំកសិផល, មន្ទីរពិសោធន៍, បន្ទប់ត្រជាក់សម្រាប់ស្តុកទុកកសិផល ជាដើម, ៥). ការផ្សព្វផ្សាយបច្ចេកទេសកសិកម្មដែលឆ្លើយតបនឹងតម្រូវការទីផ្សារ, ៦). ការអភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគុណភាព (Quality Infrastructure System) ដើម្បីឆ្លើយតបទៅនឹងតម្រូវការស្តង់ដារ សម្រាប់ការនាំចេញ, ៧). ការជំរុញការបង្កើតឧទ្យានកសិ-ឧស្សាហកម្ម (Agro-Industrial

Park), ៨). ការស្រាវជ្រាវនិងអភិវឌ្ឍន៍, ៩). ការជំរុញការអនុវត្តកិច្ចសន្យាកសិកម្ម (Contract Farming) ឱ្យកាន់តែទូលំទូលាយ, ១០). ការតភ្ជាប់កសិករ និងសហគមន៍កសិកម្មទៅកាន់ទីផ្សារ, ១១). ការពង្រឹងការអនុវត្តច្បាប់លើការត្រួតពិនិត្យគុណភាព ធាតុចូលកសិកម្ម, និង ១២). ការសម្របសម្រួលស្ថាប័ន ។

**២១. វិស័យឧស្សាហកម្ម** ត្រូវបានព្យាករថានឹងសម្រេចបានកំណើន ៥,០% ក្នុងឆ្នាំ ២០២៣ ដោយសារការថមថយកំណើនអនុវិស័យកាត់ដេរ និងការបន្តកំណើនទាបនៃអនុវិស័យសំណង់ ខណៈដែលអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរនៅបន្តរក្សាបានកំណើនល្អប្រសើរ ។ សម្រាប់ឆ្នាំ ២០២៤, វិស័យឧស្សាហកម្មត្រូវបានព្យាករថានឹងសម្រេចបានកំណើនក្នុងអត្រា ៨,៥% ទ្រទ្រង់ដោយកំណើនល្អប្រសើរនៃអនុវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ខណៈដែលអនុវិស័យសំណង់បន្តសម្រេចបានកំណើនទាបជាងនិន្នាការមុនវិបត្តិជំងឺកូវីដ-១៩ ។

**២២. អនុវិស័យកាត់ដេរ** ត្រូវបានព្យាករថានឹងមានកំណើនថមថយមកត្រឹមប្រមាណ ៤,០% ក្នុងឆ្នាំ ២០២៣ ។ កំណើនទាបក្នុងឆ្នាំ ២០២៣ នេះ បណ្តាលមកពីការថមថយតម្រូវការសកល ជាពិសេស បណ្តាប្រទេសដែលជាដៃគូពាណិជ្ជកម្មកម្ពុជា ដូចជា សហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុប ដោយសារការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ ដែលការណ៍នេះនឹងធ្វើឱ្យប៉ះពាល់ដល់សកម្មភាពចាយវាយ ហើយជាលទ្ធផលនឹងជះឥទ្ធិពលអវិជ្ជមានដល់ការបញ្ជាទិញ ។ សម្រាប់ឆ្នាំ ២០២៤, អនុវិស័យកាត់ដេរ រំពឹងថានឹងងើបឡើងវិញ ក្នុងរង្វង់ ៩,២% ស្របតាមនិន្នាការសេដ្ឋកិច្ចសកល ខណៈអត្រាអតិផរណានឹងបន្តថមថយ ។ ទោះជាយ៉ាងនេះក្តី, អនុវិស័យកាត់ដេរបន្តប្រឈមនឹងបញ្ហាមួយចំនួន ដូចជា ការកើនឡើងនូវការប្រកួតប្រជែងពីប្រទេសជិតខាង, ភាពមានកម្រិតនៃពិពិធកម្មទីផ្សារនាំចេញ និងប្រភពនៃវត្ថុធាតុ-ដើមកាត់ដេរ ព្រមទាំងភាពមានកម្រិតនៃការប្រើប្រាស់បច្ចេកវិទ្យាក្នុងចរន្តផលិតកម្ម ។ ដើម្បីធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគ, លើកកម្ពស់ភាពប្រកួតប្រជែង និងបង្កើនតម្លៃបន្ថែមនៃអនុវិស័យនេះសម្រាប់សេដ្ឋកិច្ចជាតិ, រាជរដ្ឋាភិបាលបានដាក់ចេញឱ្យអនុវត្តនូវ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២-២០២៧ ។**

**២៣. អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ** ត្រូវបានព្យាករថានឹងបន្តកំណើនក្នុងអត្រាប្រមាណ ១១,៧% ក្នុងឆ្នាំ ២០២៣ និង ១២,៨% ក្នុងឆ្នាំ ២០២៤ ដោយសារការរំពឹងទុកភាពល្អប្រសើរនៃតម្រូវការខាងក្រៅ ជាពិសេស សហរដ្ឋអាម៉េរិក, ចិន, និងអាស៊ាន ដែលនឹងបន្តលើកកម្ពស់ផលិតកម្មបម្រើឱ្យការនាំចេញលើផលិតផលដែលមានសក្តានុពលមួយចំនួន រួមមាន៖ បង្គុំសូឡា, គ្រឿងសង្ហារិម, ខ្សែភ្លើងនិងបង្គុំខ្សែភ្លើង, គ្រឿងបង្គុំអេឡិចត្រូនិក និងផលិតផលកសិ-ឧស្សាហកម្មមួយចំនួនទៀត ។ ជាមួយគ្នានេះ, ផលិតកម្មបម្រើឱ្យទីផ្សារក្នុងស្រុកក៏មាននិន្នាការកើនឡើង ជាពិសេស លើផ្នែកសំខាន់ៗ ដូចជា ផលិតកម្មដំឡើងយានយន្ត និងអាហារនិងភេសជ្ជៈ ជាដើម ។ ការបន្តអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដូចជា **កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់, កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន**, និង**កម្ពុជា-កូរ៉េ** ក៏នឹងចូលរួមចំណែកជំរុញពិពិធកម្មទាំងក្នុងផ្នែកផលិតផល និងទីផ្សារនាំចេញសម្រាប់កម្ពុជា ស្របពេលដែលការអនុវត្ត**ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា** នឹងបន្តបង្កើនភាពទាក់ទាញដល់ការវិនិយោគក្នុងអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ។ យ៉ាងណាមិញ, កង្វះវត្ថុធាតុដើម, កង្វះប្រភេទអាជីវកម្ម

ធុនតូចនិងមធ្យម និងកម្លាំងពលកម្មជំនាញក្នុងស្រុក, បញ្ហាស្ថិរភាព និងថ្លៃអគ្គិសនី, និងភាពមានកម្រិតក្នុងការតភ្ជាប់ទៅនឹងខ្សែច្រវាក់តម្លៃក្នុងតំបន់ នៅតែជាបញ្ហាប្រឈមចម្បងក្នុងអនុវិស័យនេះ ។ រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្តវិធានការមុតស្រួច ដើម្បីដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ និងបញ្ហាផ្សេងៗដែលមានចរិតអន្តរស្ថាប័ន សំដៅលើកកម្ពស់ផលិតកម្មក្នុងស្រុក, ព្រមទាំងបានដាក់ចេញឱ្យអនុវត្តនូវ "**ផែនការមេអភិវឌ្ឍន៍វិស័យថាមពល ២០២១-២០៤០**" និង "**គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល ២០២២-២០៣០**" ដែលនឹងរក្សាស្ថិរភាពការផ្គត់ផ្គង់អគ្គិសនី និងបង្កើនភាពប្រកួតប្រជែង តាមរយៈការកាត់បន្ថយថ្លៃចំណាយ និងការបង្កើនប្រសិទ្ធភាពថាមពល ។

**២៤. អនុវិស័យសំណង់** ត្រូវបានព្យាករថានឹងបន្តសម្រេចបានអត្រាកំណើនទាបក្នុងរង្វង់ ០,៦% និង ២,៤% សម្រាប់ឆ្នាំ ២០២៣ និង ២០២៤ រៀងគ្នា ដោយសារការរំពឹងទុកការបន្តងើបឡើងយឺតនៃវំហូរវិនិយោគទុនពីបរទេស ជាពិសេស សម្រាប់សំណង់ថ្លៃខ្ពស់ រួមមាន ខុនដូរ និងសំណង់បម្រើឱ្យវិស័យពាណិជ្ជកម្ម និងទេសចរណ៍, ខណៈការវិនិយោគក្នុងស្រុកនឹងនៅបន្តមានកំណើន ពិសេស សម្រាប់លំនៅឋានថ្លៃទាប ដោយអត្រានៃការរៀបចំគ្រួសារ និងតម្រូវការលំនៅឋាននៅតែកើនឡើង។ ជាពិសេស សកម្មភាពសំណង់បម្រើឱ្យវិស័យឧស្សាហកម្ម និងសេវាកម្មមួយចំនួន ដូចជា រោងចក្រផលិតកម្ម និងអគារផ្សារទំនើប ជាដើម នឹងក្លាយជានិន្នាការថ្មីក្នុងបរិបទក្រោយវិបត្តិជំងឺកូវីដ-១៩, ដែលនឹងចូលរួមទ្រទ្រង់ការអភិវឌ្ឍអនុវិស័យនេះផងដែរ ។ រាជរដ្ឋាភិបាលនឹងបន្តតាមដានដោយយកចិត្តទុកដាក់ខ្ពស់លើ ការវិវត្តនៃអនុវិស័យនេះ ដើម្បីដាក់ចេញគោលនយោបាយអន្តរាគមន៍ឱ្យបានទាន់ពេល សំដៅបញ្ចៀសហានិភ័យដែលអាចកើតមានជាយថាហេតុ ដោយទំនាក់ទំនងខ្លាំងរវាងអនុវិស័យនេះជាមួយនឹងវិស័យហិរញ្ញវត្ថុ ។

**២៥. វិស័យសេវាកម្ម** ត្រូវបានព្យាករថានឹងបន្តនិន្នាការកើនឡើង ក្នុងអត្រា ៨,១% ក្នុងឆ្នាំ ២០២៣ និង ៦,៩% ក្នុងឆ្នាំ ២០២៤ ដោយការបន្តកើនឡើងនូវសកម្មភាពក្នុងអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន និងសេវាកម្មគាំទ្រផ្សេងទៀត ដូចជា អនុវិស័យលក់ដុំ-រាយ និងអនុវិស័យដឹកជញ្ជូននិងគមនាគមន៍ ខណៈដែលអនុវិស័យអចលនទ្រព្យរំពឹងថានៅបន្តសម្រេចបានកំណើនទាបជាងនិន្នាការធម្មតា ។

**២៦. អនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន** ត្រូវបានព្យាករថានឹងមានកំណើនល្អប្រសើរក្នុងអត្រា ៤១,៥% ក្នុងឆ្នាំ ២០២៣ ដែលទ្រទ្រង់ដោយការកើនឡើងគួរឱ្យកត់សម្គាល់នៃការមកដល់របស់ទេសចរអន្តរជាតិ គួបផ្សំនឹងការកើនឡើងនៃទេសចរជាតិ ដែលជាលទ្ធផលនៃ (១). ការសម្រេចបាននូវភាពស៊ាំសហគមន៍នៅកម្ពុជា ដែលបន្តបង្កើនទំនុកចិត្តក្នុងការធ្វើដំណើរដល់ទេសចរដែលធ្វើដំណើរកម្សាន្តនៅកម្ពុជា, (២). ការលុបចោលនូវរបាំងនានាទាក់ទងនឹងគោលនយោបាយរឹតបន្តឹងការធ្វើដំណើរផ្សេងៗ ទាំងក្នុងប្រទេស, កម្រិតសកល និងក្នុងតំបន់ ដែលបានអនុញ្ញាតឱ្យសកម្មភាពទេសចរណ៍ និងសកម្មភាពសង្គម-សេដ្ឋកិច្ចបន្តវិលទៅរកប្រក្រតីភាពវិញ, (៣). ការដកចេញនូវគោលនយោបាយគ្មានកូវីដរបស់ប្រទេសចិន ដែលជាទីផ្សារទេសចរណ៍សំខាន់របស់កម្ពុជា, (៤). ការប្រារព្ធព្រឹត្តិការណ៍កីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេមក្នុងឆ្នាំ ២០២៣, និង (៥). ភាពកាន់តែល្អប្រសើរនៃសេវាកម្មទេសចរណ៍ និងកន្លែងកំសាន្ត ស្របពេលដែលហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយធ្វើដំណើរកាន់តែមានភាពងាយស្រួលជាងមុន ។ សម្រាប់ឆ្នាំ ២០២៤, អនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន ត្រូវបានព្យាករថានឹងបន្តនិន្នាការកើនឡើងជាមួយនឹង



Telegram: t.me/economyfinance

អត្រាកំណើន ១៥,៧% គាំទ្រដោយការរំពឹងទុកការបន្តងើបឡើងវិញនៃវិហូរចូលកាន់តែច្រើននូវទេសចរអន្តរជាតិ និងទេសចរជាតិ ដែលទាក់ទាញដោយការបន្តជំរុញការកែលម្អហេដ្ឋារចនាសម្ព័ន្ធ, បរិស្ថាន ក្នុង និងជុំវិញតំបន់ទេសចរណ៍ និងការបង្កើនទីផ្សារគោលដៅ ។ ប៉ុន្តែ, ទីផ្សារទេសចរណ៍នៅកម្ពុជាប្រឈមនឹងការប្រកួតប្រជែងខ្ពស់នៅក្នុងតំបន់ គួបផ្សំនឹងបញ្ហាជារចនាសម្ព័ន្ធមួយចំនួន រួមមាន៖ ភាពមានកម្រិតនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, សមត្ថភាពស្ថាប័ន និងការវិនិយោគលើការផ្សព្វផ្សាយទិសដៅទេសចរណ៍សំខាន់ៗ, ផលិតផល និងសេវាទេសចរណ៍ ព្រមទាំងការខាតបង់តម្លៃបន្ថែមសេដ្ឋកិច្ច ដោយសារភាពមានកម្រិតនៃវិស័យឧស្សាហកម្ម និងសេវាកម្មគាំទ្រ ។ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងបន្តយកចិត្តទុកដាក់លើការជំរុញទេសចរណ៍ជាតិ តាមរយៈការបន្តជំរុញការអនុវត្ត **វិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង** និង **ផែនការមេអភិវឌ្ឍន៍វិស័យទេសចរនៅខេត្តសំខាន់ៗ** សំដៅស្តារ និងលើកកម្ពស់វិស័យទេសចរណ៍ក្រោយវិបត្តិជំងឺកូវីដ-១៩ ។

**២៧. អនុវិស័យលក់ដុំ-រាយ** ត្រូវបានព្យាករថានឹងបន្តនិន្នាការកើនឡើង ក្នុងអត្រា ៦,៩% និង ៧,០% រៀងគ្នា ក្នុងឆ្នាំ ២០២៣ និង ២០២៤ គាំទ្រដោយការបន្តកើនឡើងសកម្មភាពចាយវាយក្នុងស្រុក គួបផ្សំនឹងការបន្តងើបឡើងនៃវិស័យទេសចរណ៍ ។ ទន្ទឹមនេះ, ការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាជន និងអាជីវកម្ម មកប្រើប្រាស់ឌីជីថល ដែលជួយសម្រួល និងគាំទ្រដល់សកម្មភាពទិញ-លក់ទំនិញនិងសេវាកម្មផ្សេងៗ ក៏ជាផ្នែកមួយសំខាន់ក្នុងការបង្កើនតម្លៃបន្ថែមក្នុងអនុវិស័យនេះ ខណៈការបន្តអនុវត្តនូវវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាលក្នុងឆ្នាំ ២០២៣ នេះ ក៏នឹងចូលរួមចំណែកគាំទ្រដល់សកម្មភាពចាយវាយ និងប្រើប្រាស់ផងដែរ ។

**២៨. អនុវិស័យអចលនទ្រព្យ** មាននិន្នាការដូចគ្នាទៅនឹងអនុវិស័យសំណង់ ត្រូវបានព្យាករថានឹងងើបឡើង-វិញក្នុងអត្រាកំណើនទាប ក្នុងរង្វង់ ០,៧% និង ២,៧% រៀងគ្នា សម្រាប់ឆ្នាំ ២០២៣ និង ឆ្នាំ ២០២៤ ដោយសារការរំពឹងទុកការងើបឡើងវិញយឺតនៃសកម្មភាពទិញ-លក់ និងជួលអចលនទ្រព្យថ្លៃខ្ពស់ រួមមាន ខុនដូរ និងអាផាតមិន ស្របពេលដែលនិន្នាការនៃការវិនិយោគ និងតម្រូវការ ពោលគឺចរន្តទិញ-លក់លំនៅឋាន ជាពិសេសលំនៅឋានថ្លៃទាបរំពឹងថានៅបន្តមានសកម្មភាព ។ គួរបញ្ជាក់ផងដែរថា, ការដាក់ចេញនូវកញ្ចប់វិធានការគោលនយោបាយរបស់រាជរដ្ឋាភិបាលនាពេលថ្មីៗនេះ ក៏ជួយរក្សាលំនឹងអាជីវកម្មរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ ក៏ដូចជាកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរលើអាជីវកម្មអចលនវត្ថុ ជាពិសេសផ្នែកលំនៅឋាន នឹងចូលរួមរក្សាលំនឹងដល់វិស័យអចលនទ្រព្យ ផងដែរ ។ ដូចគ្នាទៅនឹងអនុ-វិស័យសំណង់, ដោយទំនាក់ទំនងនៃអនុវិស័យនេះ ជាមួយនឹងវិស័យហិរញ្ញវត្ថុ ទាំងក្នុង និងក្រៅប្រព័ន្ធធនាគារមានកម្រិតខ្ពស់, រាជរដ្ឋាភិបាលនឹងបន្តតាមដានលើការវិវត្តនៃអនុវិស័យនេះ សំដៅដាក់ចេញនូវវិធានការអន្តរាគមន៍ផ្សេងៗ ក្នុងករណីចាំបាច់ ដើម្បីបញ្ចៀសហានិភ័យ ដែលអាចកើតមានឡើង ។

**២៩. អនុវិស័យដឹកជញ្ជូន និងគមនាគមន៍** ត្រូវបានព្យាករថានឹងបន្តសម្រេចបានកំណើនខ្ពស់ក្នុងរង្វង់ ៧,៩% និង ៨,០% ក្នុងឆ្នាំ ២០២៣ និងឆ្នាំ ២០២៤ រៀងគ្នា ដោយសារការបន្តនិន្នាការកើនឡើងនៃសកម្មភាពដឹកជញ្ជូន និងទូរគមនាគមន៍ ។ ការបន្តកើនឡើងនៃសកម្មភាពដឹកជញ្ជូន ( ផ្លូវទឹក, អាកាស និងគោក) គាំទ្រដោយការបន្តងើបឡើង-វិញនូវកំណើនក្នុងអនុវិស័យកាត់ដេរ, អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ និងអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន

ព្រមទាំងការកើនឡើងនូវនិន្នាការដឹកជញ្ជូនថ្មីៗ រួមមាន ការដឹកជញ្ជូនទំនិញឆាប់រហ័សក្នុងស្រុក (express service) និងការដឹកជញ្ជូនទំនិញដល់គោលដៅអ្នកប្រើប្រាស់ចុងក្រោយ (last-mile delivery) ផងដែរ ។ ទន្ទឹមនេះ, អនុវិស័យគមនាគមន៍ក៏បន្តនិន្នាការកើនឡើង ដោយសារការបន្តផ្លាស់ប្តូរឥរិយាបថរបស់ប្រជាជន ធុរជន និងរដ្ឋ ក្នុងការចាប់យក និងប្រើប្រាស់បច្ចេកវិទ្យាឌីជីថល សម្រាប់អនុវត្តកិច្ចការប្រចាំថ្ងៃ ។ យ៉ាងណាមិញ, អនុវិស័យនេះ បន្តជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន រួមមាន ភាពទន់ខ្សោយនៃប្រព័ន្ធដឹកជញ្ជូន, ថ្លៃខ្ពស់នៃឡូជីស្ទីក និងភាពមានកម្រិតនៃការផ្គត់ផ្គង់សេវាអ៊ីនធឺណិត ទាំងក្នុងក្របខណ្ឌវិសាលភាព, ស្ថិរភាព និងល្បឿន ។ រាជរដ្ឋាភិបាល បាននិងកំពុងបន្តជំរុញការអនុវត្ត **ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥** សំដៅបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងលើកកម្ពស់ការចាប់យកឌីជីថលនៅកម្ពុជា ព្រមទាំងពន្លឿនការដាក់ចេញ និងអនុវត្តនូវ **ផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូនអន្តរមធ្យោបាយកម្ពុជា** ដើម្បីបង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ។

**តារាងទី១÷ កំណើនសេដ្ឋកិច្ចតាមវិស័យ**

| កំណើន (%) | ២០២២ | ២០២៣ ប៉ាន់. | ២០២៤ ព្យ. |
|---|---|---|---|
| **កំណើន ផសស** | **៥,២** | **៥,៦** | **៦,៦** |
| **វិស័យកសិកម្ម** | **០,៧** | **០,៩** | **១,១** |
| ដំណាំ | ១,១ | ១,៤ | ១,៧ |
| នេសាទ | ០,២ | ០,៤ | ០,៦ |
| ការចិញ្ចឹមសត្វ | ១,០ | ០,៨ | ០,៩ |
| ព្រៃឈើ | -១,៥ | -១,៤ | -១,៥ |
| **វិស័យឧស្សាហកម្ម** | **៨,៣** | **៥,០** | **៨,៥** |
| កាត់ដេរ | ១០,៨ | ៤,០ | ៩,២ |
| សំណង់ | ០,៥ | ០,៦ | ២,៤ |
| កម្មន្តសាលមិនមែនកាត់ដេរ | ១២,២ | ១១,៧ | ១២,៨ |
| **វិស័យសេវាកម្ម** | **៤,៦** | **៨,១** | **៦,៩** |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ៣០,០ | ៤១,៥ | ១៥,៧ |
| លក់ដុំ-រាយ | ៤,៣ | ៦,៩ | ៧,០ |
| អចលនទ្រព្យ | ០,២ | ០,៧ | ២,៧ |
| ដឹកជញ្ជូន និងគមនាគមន៍ | ៦,១ | ៧,៩ | ៨,០ |

ប្រភព÷ ការប៉ាន់ស្មាន និងការព្យាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ខែ ឧសភា ឆ្នាំ ២០២៣។



Telegram: t.me/economyfinance

៣០. **អត្រាអតិផរណា** ត្រូវបានរំពឹងថានឹងត្រឡប់ទៅរកនិន្នាការធម្មតាវិញ ក្នុងអត្រា ២,៥% ដូចគ្នា សម្រាប់ឆ្នាំ ២០២៣ និងឆ្នាំ ២០២៤ ដោយសារការរំពឹងទុកការវិលទៅរកប្រក្រតីភាពវិញនៃថ្លៃប្រេងអន្តរជាតិ និងថ្លៃទំនិញផ្សេងៗទៀត ។ **អត្រាប្តូរប្រាក់** ត្រូវបានរំពឹងថានឹងស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន ក្នុងអត្រាជាមធ្យមប្រចាំឆ្នាំប្រមាណ ៤ ០៦៥ រៀលក្នុងមួយដុល្លារអាមេរិក ក្នុងឆ្នាំ ២០២៣ និងឆ្នាំ ២០២៤ គាំទ្រដោយអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជា ក្នុងការរក្សាស្ថិរភាពថ្លៃ និងទំនុកចិត្តពីសាធារណជនលើការប្រើប្រាស់ប្រាក់រៀល ។

៣១. **ឱនភាពគណនីចរន្ត** (រួមបញ្ចូលបង្វែរ) ត្រូវបានព្យាករថានឹងបន្ធូរមកតូចមកវិញ ក្នុងទំហំប្រមាណ ១០,៧% និង ៩,៦% នៃ ផសស រៀងគ្នា សម្រាប់ឆ្នាំ ២០២៣ និងឆ្នាំ ២០២៤ ក្រោមការរំពឹងទុកការបន្តវិលត្រឡប់ទៅរកប្រក្រតីភាពវិញនៃសមតុល្យពាណិជ្ជកម្ម ស្របពេលដែលចំណូលពីភ្ញៀវទេសចរអន្តរជាតិ និងប្រាក់បង្វែរឯកជនក៏បន្តនិន្នាការកើនឡើង ។ ជាមួយគ្នានេះ, **វិហ្វូវិនិយោគផ្ទាល់ពីបរទេស** សម្រាប់ឆ្នាំ ២០២៣ និង ២០២៤ ត្រូវបានរំពឹងថានឹងបន្តកើនឡើងក្នុងរង្វង់ ១២,១% និង ១២,៣% នៃ ផសស រៀងគ្នា ដោយសារការបន្តកើនឡើងនៃទំនុកចិត្តវិនិយោគ ក្នុងបរិការណ៍នៃការផ្លាស់ប្តូរកាន់តែលឿននៃខ្សែច្រវាក់ផលិតកម្ម និងផ្គត់ផ្គង់តំបន់ និងសកល មកតំបន់អាស៊ាន ជាមួយនឹងបរិយាកាសវិនិយោគកាន់តែអំណោយផលរបស់កម្ពុជា ដែលជាផ្លែផ្កានៃការបន្តការអនុវត្តកំណែទម្រង់កាន់តែស៊ីជម្រៅ និងមុតស្រួច ។ **ទុនបម្រុងអន្តរជាតិសរុប** រំពឹងថានឹងបន្តកើនឡើងដល់ ១៩ ៤៣៧ និង ២១ ២៨៥ លានដុល្លារអាមេរិក ដែលធានាការនាំចូលបានប្រមាណ ៦,៩ និង ៦,៦ ខែ រៀងគ្នា សម្រាប់ឆ្នាំ ២០២៣ និងឆ្នាំ ២០២៤ ។

**តារាងទី២៖ តារាងប៉ាន់ស្មានទំហំពាណិជ្ជកម្ម និងវិនិយោគផ្ទាល់ពីបរទេស**

| សូចនាករ | ២០២២ | ២០២៣ ប៉ាន់. | ២០២៤ ព្យា. |
|---|---|---|---|
| ការនាំចេញ (លានដុល្លារអាមេរិក) | ២៣ ១៧៩ | ២៥ ០១៥ | ២៩ ១៧២ |
| ការនាំចូល (លានដុល្លារអាមេរិក) | ៣២ ០០៥ | ៣១ ០៧០ | ៣៥ ៤០៣ |
| ឱនភាពគណនីចរន្ត (លានដុល្លារអាមេរិក) | ៧ ៥៨២ | ៣ ៤៥៤ | ៣ ៣៦៤ |
| វិហ្វូទុនវិនិយោគបរទេស (លានដុល្លារអាមេរិក) | ៣ ៥៧៩ | ៣ ៨៨៤ | ៤ ៣០៨ |
| ការនាំចេញ (ភាគរយនៃ ផសស) | ៧៨,៤% | ៧៧,៧% | ៨២,៩% |
| ការនាំចូល (ភាគរយនៃ ផសស) | ១០៨,២% | ៩៦,៦% | ១០០,៧% |
| ឱនភាពសមតុល្យពាណិជ្ជកម្មសរុប (ភាគរយនៃ ផសស) | ២៩,៨% | ១៨,៨% | ១៧,៧% |
| ឱនភាពគណនីចរន្ត (ភាគរយនៃ ផសស) | ២៥,៦% | ១០,៧% | ៩,៦% |
| វិហ្វូទុនវិនិយោគបរទេស (ភាគរយនៃ ផសស) | ១២,១% | ១២,១% | ១២,៣% |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា និងការប៉ាន់ស្មាន និងការព្យាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ខែ ឧសភា ឆ្នាំ ២០២៣ ។

៣២. ទោះជាយ៉ាងនេះក្ដី, ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជា បាននិងកំពុងហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាដែលបណ្ដាលមកពីកត្តាខាងក្រៅមួយចំនួន រួមមាន÷

១). ការកើនឡើងនូវភាពតានតឹងភូមិសាស្ត្រនយោបាយតំបន់ និងសកល,

២). ការថមថយនូវកំណើនសេដ្ឋកិច្ចសកល និងការកើនឡើងសម្ពាធអតិផរណា,

៣). ការបន្តរឹតបន្តឹងយូរជាងការរំពឹងទុកនៃគោលនយោបាយរូបិយវត្ថុ ជាពិសេសសហរដ្ឋអាមេរិក និងការកើនឡើងថ្លៃរូបិយបណ្ណដុល្លារអាមេរិក ដែលអាចប៉ះពាល់ដល់លំហូរទុនវិនិយោគ និងពាណិជ្ជកម្ម,

៤). ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ច កំពុងកាត់បន្ថយនូវការចូលរួមក្នុងចរន្តសកលភាវូបនីយកម្ម ស្របជាមួយនឹងការកើនឡើងនៃនិន្នាការពហុប៉ូល និងការបែកចែកប្លុកសេដ្ឋកិច្ច និងពាណិជ្ជកម្ម, និង

៥). ការកើនឡើងនូវផលប៉ះពាល់ជាអវិជ្ជមានកាន់តែធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ ។

៣៣. ទន្ទឹមនេះ, កម្ពុជាក៏នៅតែបន្តប្រឈមនឹងបញ្ហាជារចនាសម្ព័ន្ធខាងក្នុងមួយចំនួន ដែលធ្វើឱ្យការធ្វើពិពិធកម្មសេដ្ឋកិច្ចមានល្បឿនយឺត និងភាពប្រកួតប្រជែងមានកម្រិត រួមមាន÷

១). ថ្លៃដើមធ្វើធុរកិច្ចនៅមានកម្រិតខ្ពស់,

២). ភាពមានកម្រិតនៃកិច្ចសម្រួលពាណិជ្ជកម្ម និងបរិយាកាសធុរកិច្ច,

៣). ភាពមានកម្រិតនៃកម្លាំងពលកម្មជំនាញ ទាំងបរិមាណ និងគុណភាព ដែលមិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារ,

៤). ភាពមានកម្រិតនៃប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម, និង

៥). ភាពមានកម្រិតនៃចំណេះដឹង និងជំនាញក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល ។

បន្ថែមលើនេះ, កម្ពុជាក៏កំពុងប្រឈមនឹងហានិភ័យនៃការកើនឡើងខ្ពស់នៃបំណុលឯកជនផងដែរ ដែលការណ៍នេះអាចនឹងបង្កើតជាផលជះដល់កំណើននៃវិស័យពិត តាមរយៈការផ្សារភ្ជាប់នៃវិស័យម៉ាក្រូសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ។

៣៤. ស្ថិតក្នុងបរិការណ៍ដែលកាន់តែមានភាពមិនប្រាកដប្រជាខ្ពស់ និងការវិវត្តលឿនជាងការរំពឹងទុកនូវនិន្នាការសកល និងតំបន់, រាជរដ្ឋាភិបាលបាននិងកំពុងបន្តដាក់ចេញឱ្យអនុវត្តនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈ, គោលនយោបាយរូបិយវត្ថុ និងគោលនយោបាយជារចនាសម្ព័ន្ធប្រកបដោយភាពប្រទាក់ក្រឡាគ្នា, ព្រមទាំងរៀបចំយន្តការច្បាស់លាស់សម្រាប់បន្តជំរុញការអនុវត្តគោលនយោបាយទាំងនេះ ឱ្យកាន់តែមានប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពខ្ពស់ សំដៅបន្តរក្សាលំនឹង និងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន ។ ជាមួយគ្នានេះ, រាជរដ្ឋាភិបាលនឹងបន្តជំរុញការស្ដារ និងពង្រឹងចទល់កំណើនសេដ្ឋកិច្ច ឱ្យរស់រវើក និងត្រឡប់ទៅកំណើនសក្ដានុពល, ចាប់យកឱ្យបាននូវកាលានុវត្តភាពថ្មីៗ ដែលកំពុងលេចឡើង និងកសាងភាពធន់សង្គម-សេដ្ឋកិច្ច ឱ្យកាន់តែរឹងមាំ និងមានភាពឆ្លើយតបខ្ពស់ទៅនឹងវិបត្តិដែលអាចកើតមាន ។ សម្រាប់រយៈពេលមធ្យម និងវែងខាងមុខ, រាជរដ្ឋាភិបាលនៅបន្តការកែទម្រង់ជារចនាសម្ព័ន្ធ និងជាប្រព័ន្ធ ដោយផ្ដោតលើអាទិភាពចំនួន ៥ រួមមាន÷

- **បន្តពង្រឹងរដ្ឋបាលសាធារណៈ** តាមរយៈការបន្តកែទម្រង់ស្ថាប័នរដ្ឋ ដោយផ្តោតលើការពង្រឹងសមត្ថភាព និងប្រសិទ្ធភាពក្នុងការអនុវត្តការងារ, ការសម្រិតសម្រាំងមន្ត្រីមានសមត្ថភាពខ្ពស់និងគុណវុឌ្ឍិល្អ ឱ្យទទួលខុសត្រូវការងារសំខាន់ៗ ព្រមទាំងការលើកកម្ពស់ការទទួលខុសត្រូវ និងភាពម្ចាស់ការរបស់ក្រសួង-ស្ថាប័ន ដើម្បីឈានទៅសម្រេចបានរដ្ឋបាលសាធារណៈស្អាតស្អំ, ឆ្លាតវៃ និងមានសមត្ថភាពខ្ពស់ ។
- **បន្តជំរុញការកសាងភាពធន់នៃសេដ្ឋកិច្ច** តាមរយៈការពន្លឿនការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការលើក-កម្ពស់ភាពប្រកួតប្រជែង ដោយផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគ និងកិច្ចសម្រួលពាណិជ្ជកម្ម, ការជំរុញឌីជីថលូបនីយកម្មសង្គម-សេដ្ឋកិច្ច ទាំងវិស័យសាធារណៈ និងវិស័យឯកជនជាពិសេស ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ឡូជីស្ទីក, ថាមពលបៃតង និងឌីជីថល ប្រកបដោយគុណភាពខ្ពស់ ។
- **ពន្លឿនការកសាងភាពធន់នៃសង្គម និងប្រជាជន** តាមរយៈការបន្តអភិវឌ្ឍប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម ទាំងគុណភាព និងវិសាលភាព ដើម្បីត្រៀមខ្លួនឆ្លើយតបទៅនឹងវិបត្តិ ឬហានិភ័យនានាដែលអាចកើតឡើងជាយថាហេតុនាពេលអនាគត ព្រមទាំងការបន្តអភិវឌ្ឍធនធានមនុស្ស ដោយផ្តោតលើការពង្រឹងគុណភាពនៃវិស័យអប់រំ, ជំនាញបច្ចេកទេស ព្រមទាំងសីលធម៌ និងចរិយាធម៌របស់ពលរដ្ឋ ។
- **ជំរុញការកសាងភាពធន់នៃប្រព័ន្ធហិរញ្ញវត្ថុ** តាមរយៈការបង្កើនសមត្ថភាព និងភាពធន់នៃប្រព័ន្ធថវិកាឱ្យកាន់តែមានពិពិធភាព, រឹងមាំ, ធន់នឹងវិបត្តិ និងប្រកបដោយបរិយាបន្ន ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ច និងសង្គម ដើម្បីដើរតួជាស្នូល ក្នុងការទ្រទ្រង់សកម្មភាពសេដ្ឋកិច្ចទាំងមូល ដោយផ្តោតលើការធ្វើទំនើបកម្ម និងវិចារណកម្ម ព្រមទាំងឌីជីថលនីយកម្មប្រព័ន្ធគ្រប់គ្រងចំណូលនិងចំណាយថវិកា និងគ្រប់គ្រងបំណុលសាធារណៈឱ្យមានប្រសិទ្ធភាព និងចីរភាព, ក្នុងនោះរួមទាំងពង្រឹងស្ថានភាពសញ្ច័យរបស់រដ្ឋឡើងវិញ បន្តពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងប្រព័ន្ធឆ្លើយតបនឹងវិបត្តិរបស់ធនាគារ និងការពង្រឹងប្រព័ន្ធសុវត្ថិភាពហិរញ្ញវត្ថុ នឹងរួមចំណែកដល់ការបង្កើនប្រសិទ្ធភាពនៃការតាមដាន និងត្រួតពិនិត្យម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ការពង្រឹងការគ្រប់គ្រងវិបត្តិ និងកិច្ចសហប្រតិបត្តិការដើម្បីធានាស្ថិរភាពហិរញ្ញវត្ថុ និងភាពធន់នៃប្រព័ន្ធហិរញ្ញវត្ថុ ។
- **ជំរុញការកសាងភាពធន់នៃបរិស្ថាន និងអាកាសធាតុ** តាមរយៈការបង្កើនសមត្ថភាពក្នុងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ ដូចជាការឡើងកំដៅផែនដី និងការត្រៀមលក្ខណៈ ដើម្បីឆ្លើយតបទៅនឹងគ្រោះមហន្តរាយធម្មជាតិផ្សេងៗ ។

## ៤. ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

**៣៥.** ដើម្បីធានាការសម្រេចបាននូវទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច ចំពោះមុខ និងរយៈពេលមធ្យម ស្របតាមទិសដៅគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ក្នុងការបន្តកសាងមូលដ្ឋានគ្រឹះសង្គម-សេដ្ឋកិច្ចកម្ពុជា ប្រកបដោយចីរភាព, បរិយាបន្ន និងភាពធន់, ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៤ កំណត់យកអាទិភាពសំខាន់ៗ ដូចខាងក្រោម÷

១. បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ,

២. បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យមប្រកបដោយបរិយាបន្ន,

៣. បន្តដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ក្នុងគោលដៅលើកកម្ពស់ជីវភាពរស់នៅ, បង្កើនផលិតភាពការងារ និងពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍សមធម៌, គុណាធិបតេយ្យ និងចីរភាពថវិកា,

៤. ការបន្តស្តារ និងជំរុញកំណើនសេដ្ឋកិច្ច ឱ្យស្ទុះងើបឡើងវិញ ដើម្បីបន្តបង្កើតការងារជូនប្រជាជន, ជាពិសេសស្រទាប់យុវជន, និង ដើម្បីផ្តល់លទ្ធភាពឱ្យប្រជាជនទទួលបានប្រាក់ចំណូលខ្ពស់ឡើងវិញផង និងជំរុញបង្កើនចំណូលថវិកាជាតិផង,

៥. ជំរុញការអភិវឌ្ឍប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម និងកសាងភាពធន់នៃសង្គមកម្ពុជា ដែលអាចឆ្លើយតបទៅនឹងគ្រោះអាសន្ន ដែលអាចកើតមានជាយថាហេតុ,

៦. ជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសគ្រប់កម្រិត ដើម្បីផ្គត់ផ្គង់ពលករជំនាញ ប្រកបដោយផលិតភាពខ្ពស់ ឱ្យបានគ្រប់គ្រាន់ និងឆ្លើយតបនឹងតម្រូវការទីផ្សារ,

៧. បន្តជំរុញការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌,

៨. បន្តជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការអភិវឌ្ឍបៃតង សំដៅជំរុញការតភ្ជាប់ក្នុងសេដ្ឋកិច្ច, គាំទ្រការធ្វើបរិវត្តកម្មឌីជីថល និងអភិវឌ្ឍប្រកបដោយចីរភាព, និង

៩. បន្តគាំទ្រការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, ការដាក់ចេញវិធានការលើកទឹកចិត្តជាក់លាក់ និងការកែលម្អបរិយាកាសធុរកិច្ច ។



Telegram: t.me/economyfinance

៣៦. ផ្អែកលើមូលដ្ឋានក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងការវិវត្តជាក់ស្តែងនៃស្ថានភាពហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលដាក់ចេញនូវ **"គោលនយោបាយពង្រឹងប្រសិទ្ធភាពចំណាយ" (Fiscal Consolidation)** នៅក្នុងឆ្នាំ ២០២៤ សំដៅជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ក្នុងបរិការណ៍នៃការចាកចេញពីវិបត្តិជំងឺកូវីដ-១៩ និងលើកកម្ពស់កិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ ដោយឆ្នាំ ២០២៤ គឺជាឆ្នាំដំបូងនៃរាជរដ្ឋាភិបាល នីតិកាលទី ៧, រាជរដ្ឋាភិបាលគិតគូរយ៉ាងហ្មត់ចត់លើអាទិភាពចំណាយប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ ដើម្បីបន្តពង្រឹងសមត្ថភាពស្ថាប័ន និងលើកកម្ពស់សមត្ថភាពមន្ត្រី ពិសេស គាំទ្រដល់ការអនុវត្តកម្មវិធីគោលនយោបាយ អាទិភាពនានា ស្របពេលដែលទស្សនវិស័យនៃការប្រមូលចំណូលប្រឈមនឹងកំណើនយឺតជាងមុនវិបត្តិកូវីដ-១៩ ។

៣៧. ចំណូលចរន្ត ឆ្នាំ ២០២៤ ត្រូវបានព្យាករថានឹងសម្រេចបានកំណើនប្រសើរឡើងវិញ ជាមួយនឹងស្ថានភាពល្អនៃសេដ្ឋកិច្ចកម្ពុជា ជាពិសេស ការបន្តអនុវត្តគោលនយោបាយគាំទ្រនានារបស់រាជរដ្ឋាភិបាល សំដៅបន្តកែលម្អបរិយាកាសវិនិយោគ និងកិច្ចសម្រួលពាណិជ្ជកម្ម ដែលនឹងជួយជំរុញបន្ថែមទៀតនូវសកម្មភាពធុរកិច្ច និងពាណិជ្ជកម្មក្នុងស្រុក ឱ្យកាន់តែមានភាពមមាញឹក និងធន់នឹងវិបត្តិ ។ ក្នុងនោះ, ចំណូលសារពើពន្ធ ត្រូវបានរំពឹងថានឹងបន្តសម្រេចបានកំណើនវិជ្ជមាន ស្របតាមការបន្តរីកធំនៃមូលដ្ឋានពន្ធ ព្រមទាំងភាពល្អប្រសើរនៃការលើកកម្ពស់អនុលោមភាពអ្នកជាប់ពន្ធ ។ ការណ៍នេះ កើតចេញពីការខិតខំប្រឹងប្រែងយ៉ាងសស្រាក់សស្រាំរបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងរដ្ឋបាលសារពើពន្ធ ដែលជាចលករដ៏សំខាន់ក្នុងការជួយឱ្យចំណូលជារួម បន្តមានកំណើន ។ ជាមួយគ្នានេះ, ចំណូលមិនមែនសារពើពន្ធ ក៏ត្រូវបានរំពឹងថានឹងបន្តងើបឡើងវិញក្នុងអត្រាកំណើនខ្ពស់ ស្របតាមការរំពឹងទុកនៃការវិលត្រឡប់មកវិញនូវសកម្មភាពក្នុងវិស័យទេសចរណ៍ ព្រមទាំងការបន្តខិតខំពង្រឹងការគៀរគរចំណូលពីប្រភពនានា ដែលនៅមានសក្តានុពលខ្ពស់ ។

៣៨. ជាក់ស្តែង, ភាពល្អប្រសើរនៃការប្រមូលចំណូលជាតិ នឹងរួមចំណែកមួយផ្នែកធំ ក្នុងការទ្រទ្រង់ទ្រនាប់ថវិកាកម្ពុជា ក៏ដូចជាពង្រឹងភាពជាម្ចាស់ និងឯករាជ្យភាពរបស់កម្ពុជា សម្រាប់បំពេញតម្រូវការចំណាយ ដែលមិនបានគ្រោងទុក និងតម្រូវការចាំបាច់ផ្សេងៗទៀត ដូចជាការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា ដើម្បីចូលរួមកសាងមូលដ្ឋានគ្រឹះសេដ្ឋកិច្ច ។ ទោះជាយ៉ាងនេះក្តី, ការប្រមូលចំណូល អាចនឹងជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន រួមមាន៖ (១). ភាពមានកម្រិតនៃការតាមដាន និងវាយតម្លៃឱ្យច្បាស់លាស់ លើការអនុវត្តគោលនយោបាយលើកទឹកចិត្ត និងគោលនយោបាយអនុគ្រោះពន្ធនានា ដែលធ្វើឱ្យមានការបាត់បង់នូវប្រភពចំណូលសំខាន់ៗ, (២). មូលដ្ឋានយកពន្ធ និងអនុលោមភាពអ្នកបង់ពន្ធ នៅមានកម្រិត ជាពិសេស ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ, (៣). ភាពមានកម្រិតនៃការអនុវត្តតាមបទប្បញ្ញត្តិនានា ក្នុងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ ដោយសារបញ្ហាអភិបាលកិច្ច និងភាពមានកម្រិតនៃប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រង និង (៤). ភាពមានកម្រិតនៃប្រសិទ្ធភាពក្នុងការគ្រប់គ្រងការប្រមូលចំណូលសារពើពន្ធ និងបញ្ហាអភិបាលកិច្ច ជាដើម ។

៣៩. ក្របខណ្ឌចំណាយសាធារណៈឆ្នាំ ២០២៤ ត្រូវបានគិតគូរយ៉ាងហ្មត់ចត់ សំដៅលើកកម្ពស់កិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក្នុងបរិការណ៍នៃការចាកចេញពីវិបត្តិជំងឺកូវីដ-១៩ ។ ជាទិសដៅយុទ្ធសាស្ត្រ, គោលនយោបាយ

ចំណាយសាធារណៈឆ្នាំ ២០២៤ នឹងផ្ដោតលើទិដ្ឋភាព ៣ សំខាន់ៗ រួមមាន÷ ផ្នែកស្ថាប័ន, សង្គម និង សេដ្ឋកិច្ច ដែលមានកម្មវិធីគោលនយោបាយអាទិភាពចំនួន ៦ រួមមាន÷

១. ការបន្តពង្រឹងសមត្ថភាពរបស់មន្ត្រីរាជការ និងបន្ថែមការលើកទឹកចិត្តចំពោះមន្ត្រីដែលមានគុណវុឌ្ឍិ តាមរយៈការដំឡើងបៀវត្ស និងកម្មវិធីពង្រឹងសមត្ថភាពជំនាញមន្ត្រីរាជការ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពក្នុងការអនុវត្តការងារ,

២. ការបន្តពង្រឹងប្រព័ន្ធគាំពារសង្គមចំគោលដៅ តាមរយៈការធ្វើស្ថាប័នូបនីយកម្មគ្រប់គ្រងឱ្យកាន់តែមានប្រសិទ្ធភាព ព្រមទាំងពង្រីកវិសាលភាពគ្របដណ្ដប់ ដើម្បីលើកកម្ពស់ជីវភាពប្រជាជនចាស់ជរា និងងាយរងគ្រោះ ព្រមទាំងនិយោជិត ដែលស្ថិតនៅក្រៅប្រព័ន្ធ,

៣. ការបន្តអភិវឌ្ឍមូលធនមនុស្ស តាមរយៈការលើកកម្ពស់ ទាំងការអប់រំ និងការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ ឱ្យស្របតាមតម្រូវការទីផ្សារការងារ,

៤. ការបង្កើនការវិនិយោគក្នុងវិស័យដែលជាប្រភពកំណើនថ្មី និងមានសក្ដានុពលសេដ្ឋកិច្ច និងផលិតភាពខ្ពស់ ដែលនឹងរួមចំណែកទ្រទ្រង់ដល់ចីរភាព, ភាពធន់ និងបរិយាប័ន្ន នៃកំណើនសេដ្ឋកិច្ច,

៥. ការបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងបៃតង ស្របតាមការដាក់ចេញក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, និង

៦. ការពង្រឹងភាពប្រកួតប្រជែង និងពិពិធកម្មសេដ្ឋកិច្ច ក្នុងវិស័យសក្ដានុពលនានា រួមមាន វិស័យកសិកម្ម, ដឹកជញ្ជូន និងឡូជីស្ទីក និង សហគ្រាសធុនតូចនិងមធ្យម (SMEs) ដែលជាចន្ទល់កំណើនសេដ្ឋកិច្ចកម្ពុជា ។

**៤០.** សម្រាប់ឆ្នាំ ២០២៤, កញ្ចប់ចំណាយវិនិយោគសាធារណៈ ត្រូវបានរៀបចំប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ ដែលក្នុងនោះត្រូវបានគិតគូរដល់តម្រូវការថវិកាចាំបាច់នានា ក្នុងការវិនិយោគលើមូលធនមនុស្ស, ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងបៃតង និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលមានគុណភាព និងផលត្រឡប់ខ្ពស់ ព្រមទាំងចំណាយសម្រាប់ដោះស្រាយផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍នានាផងដែរ ។ ចំពោះចំណាយចរន្ត, ក្នុងនោះចំណាយបន្ទុកបុគ្គលិក ត្រូវបានរៀបចំឱ្យមានការដំឡើងប្រាក់បៀវត្សអប្បបរមាជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ក្នុងកម្រិតខ្ពស់ជាងអត្រាអតិផរណាបន្តិច ដើម្បីលើកកម្ពស់សុខុមាលភាព និងពង្រឹងសមត្ថភាពជំនាញរបស់មន្ត្រីរាជការ ខណៈចំណាយក្រៅបន្ទុកបុគ្គលិកត្រូវបានបង្កើន ពិសេស ចំណាយមិនទាន់បែងចែក ដើម្បីផ្ដល់នូវលទ្ធភាពគ្រប់គ្រាន់ដល់រាជរដ្ឋាភិបាលនីតិកាលទី ៧ ក្នុងការអនុវត្តគោលនយោបាយអាទិភាពថ្មីៗ និងការត្រៀមបម្រុងសម្រាប់ដោះស្រាយហានិភ័យនានា ។

**៤១.** ដើម្បីសម្រេចគោលបំណងនៃក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈខាងលើ, រាជរដ្ឋាភិបាលកំណត់គោលដៅសូចនាករហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៤ ដូចខាងក្រោម÷

- ចំណូលសរុបត្រូវបានគ្រោងប្រមាណ ២៣,០៧%នៃ ផសស ក្នុងនោះ÷
  - ចំណូលចរន្តត្រូវបានគ្រោងសម្រេចឱ្យបានក្នុងទំហំ ២២,៣៣% នៃ ផសស និងមានកំណើន ១១,៨% ធៀបនឹងការប៉ាន់ស្មានចំណូលចរន្តក្នុងឆ្នាំ ២០២៣ ឬ ១៣,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ

ឆ្នាំ ២០២៣ ដែលក្នុងនោះ ថ្នាក់ជាតិត្រូវគ្រោងសម្រេចឱ្យបានប្រមាណ ២០,៤៦% នៃ ផសស និងថ្នាក់ក្រោមជាតិប្រមាណ ១,៨៧% នៃ ផសស ។

- ○ សម្រាប់ការប្រមូលចំណូលតាមអគ្គនាយកដ្ឋាន÷ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវគ្រោងសម្រេចឱ្យបាន ៧,៧៨% នៃ ផសស, អគ្គនាយកដ្ឋានពន្ធដារ ត្រូវគ្រោងសម្រេចឱ្យបាន ១១,៧៥% នៃ ផសស និង ចំណូលមិនមែនសារពើពន្ធ ត្រូវគ្រោងសម្រេចឱ្យបាន ២,៧៦% នៃ ផសស ។
- ○ ចំណូលផ្សេងៗត្រូវគ្រោងសម្រេចឱ្យបានប្រមាណ ០,៧៤% នៃ ផសស ។

- ចំណាយសរុបថវិការដ្ឋត្រូវបានគ្រោងក្នុងរង្វង់ ២៦,២៥% នៃ ផសស ក្នុងនោះ ចំណាយសរុបថវិកាថ្នាក់ជាតិមានប្រមាណ ២៤,៤២% នៃ ផសស និងចំណាយសរុបថវិកាថ្នាក់ក្រោមជាតិប្រមាណ ២,៩៦% នៃ ផសស ដោយរួមបញ្ចូលទាំងការឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិ ចំនួន ១,០៥% នៃ ផសស ។
  - ○ ចំណាយចរន្តថវិការដ្ឋត្រូវបានគ្រោងក្នុងរង្វង់ ១៨,៤៣% នៃ ផសស ដែលក្នុងនោះ ចំណាយបន្ទុកបុគ្គលិកមានសមាមាត្រស្មើនឹង ៤១,៨% នៃចំណាយចរន្តសរុប ត្រូវជា ៧,៧០% នៃ ផសស និងចំណាយក្រៅបន្ទុកបុគ្គលិកមានសមាមាត្រស្មើនឹង ៥៨,២% នៃចំណាយចរន្តសរុប ត្រូវជា ១០,៧៣% នៃ ផសស ។
  - ○ ចំណាយមូលធនត្រូវបានគ្រោងក្នុងរង្វង់ ៧,៨៥% នៃ ផសស ដែលក្នុងនោះ ចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវបានគ្រោងក្នុងរង្វង់ ៣,៥១% នៃ ផសស និងចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានគ្រោងក្នុងរង្វង់ ៤,៣៤% នៃ ផសស ។

**៤២.** ចំណាយថ្នាក់ជាតិ ដែលរួមបញ្ចូលទាំងចំណាយចរន្ត និងចំណាយមូលធនសម្រាប់ឆ្នាំ ២០២៤ ត្រូវបានគ្រោងវិភាជទៅតាមវិស័យ ដូចខាងក្រោម÷

១. **ចំណាយវិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងប្រមាណ ១,៩៥% នៃ ផសស សំដៅបន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងការទូត និងការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។

២. **ចំណាយវិស័យការពារជាតិ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងប្រមាណ ៣,៨៣% នៃ ផសស សំដៅគាំទ្រការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, ការលើកកម្ពស់សុខុមាលភាព និងការពង្រឹងសមត្ថភាពរបស់កងកម្លាំងប្រដាប់អាវុធ ក្នុងបុព្វហេតុធានាកិច្ចការពារជាតិ និងរក្សាសន្តិភាព និងស្ថិរភាពនយោបាយ ។

៣. **ចំណាយវិស័យសង្គមកិច្ច** ត្រូវបានគ្រោងប្រមាណ ៦,៤៨% នៃ ផសស សំដៅបន្តលើកកម្ពស់គុណភាព និងពង្រីកវិសាលភាពនៃការទទួលបានសេវាសុខាភិបាល, ពង្រឹងប្រព័ន្ធសុខភាពសាធារណៈ ដែលអាច

ឆ្លើយតបនឹងគ្រោះអាសន្ននាពេលអនាគត, បន្តវិនិយោគលើគោលនយោបាយលើកកម្ពស់ការអប់រំ, ព្រមទាំងគាំទ្រដល់ការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០១៦-២០២៥, គោលនយោបាយជាតិ ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ ២០១៧-២០២៥, និងគោលនយោបាយអាទិភាព ផ្សេងទៀត លើផ្នែកសង្គមកិច្ច, សាសនា, វប្បធម៌ និងបរិស្ថាន ជាពិសេស ការប្រែប្រួលអាកាសធាតុ ។

៤. **ចំណាយវិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងប្រមាណ ៦,៩៩% នៃ ផសស ដោយផ្តោតសំខាន់លើការគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម, ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២-២០២៧, យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ ២០២០-២០៣០, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥, គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម ២០២១-២០៣០, និងការអនុវត្តផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុងនិងក្រោយវិបត្តិជំងឺកូវីដ-១៩ ឆ្នាំ ២០២០-២០២៥, ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ ២០២១-២០៣៥ និង ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី ២០២១-២០៣៥ ជាដើម ។

៥. **ចំណាយផ្សេងៗ** ត្រូវបានគ្រោងប្រមាណ ៥,១៣% នៃ ផសស ដើម្បីធានាបាននូវលទ្ធភាពអន្តរាគមន៍ភ្លាមៗក្នុងការដោះស្រាយនូវបញ្ហាសង្គម-សេដ្ឋកិច្ច និងត្រៀមបម្រុងសម្រាប់ការអនុវត្តគោលនយោបាយអាទិភាពនានា, ការឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងកិច្ចការបន្ទាន់ចំពោះមុខរបស់រាជរដ្ឋាភិបាលដូចជាការត្រៀមបម្រុងសម្រាប់គ្រោះមហន្តរាយធម្មជាតិ និងស្បៀងបម្រុង ។ល។ ដោយឡែក, សម្រាប់ការអនុវត្តជាក់ស្តែង, ចំណាយថវិកាដែលបានគ្រោងក្នុងផ្នែកចំណាយផ្សេងៗនេះ នឹងត្រូវវិភាជទៅតាមវិស័យទាំង ៤ ខាងលើ ស្របតាមគោលដៅនៃមុខចំណាយនីមួយៗ ។

**៤៣.** ដោយឈរលើមូលដ្ឋានក្របខណ្ឌចំណូល និងចំណាយខាងលើ, អតិរេកថវិកាចរន្ត សម្រាប់ឆ្នាំ ២០២៤ នឹងស្ថិតក្នុងរង្វង់ ៣,៨៩% នៃ ផសស និង ឱនភាពថវិកាសរុប ស្ថិតក្នុងរង្វង់-៣,២២% នៃ ផសស(សូមពិនិត្យក្របខណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៣-២០២៦ ក្នុងឧបសម្ព័ន្ធ ២) ។

## ៤.១ វិធានការផ្នែកចំណូល

**៤៤.** ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនានាលើការប្រមូលចំណូល សំដៅទ្រទ្រង់ចលនការនៃការគាំទ្រចីរភាពកំណើនសេដ្ឋកិច្ច, កន្លងទៅ, រាជរដ្ឋាភិបាលបានខិតខំជំរុញការអនុវត្តនូវ **យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣** ជាពិសេស បន្តពង្រឹង និងកែលម្អគោលនយោបាយ និងការគ្រប់គ្រងចំណូល ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសេនាធិការ បានគិតគូរនិងកំពុងរៀបចំ **ក្របខណ្ឌយុទ្ធសាស្ត្រកៀរគរ**

**ចំណូល** ដំណាក់កាលបន្ទាប់ ក្នុងគោលដៅបន្តពង្រឹងការកៀរគរ និងគ្រប់គ្រងចំណូល រួមមានជាអាទិ៍ ការកសាងក្របខណ្ឌគោលនយោបាយសម្រាប់ត្រៀមលក្ខណៈអនុវត្តពន្ធលើប្រាក់ចំណេញមូលធន និងប្រាក់ចំណូលរូបវន្តបុគ្គល, ការកែលម្អគោលនយោបាយអាករពិសេស និងការសិក្សាដើម្បីរៀបចំឡើងវិញនូវប្រព័ន្ធសារពើពន្ធកម្ពុជា ដើម្បីបន្តអភិវឌ្ឍប្រព័ន្ធចំណូលរដ្ឋ ដែលអាចឆ្លើយតបបានទៅនឹងការវិវត្តនៃសង្គម-សេដ្ឋកិច្ច ព្រមទាំងធានាការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាព, យុត្តិធម៌ និងសមធម៌សង្គម ។ ជាមួយគ្នានេះ, វិធានការគន្លឹះបន្ថែម ត្រូវបានកំណត់ដូចខាងក្រោម÷

**ក. វិធានការផ្នែកពន្ធដារ**

**៤៥.** វិធានការគន្លឹះសម្រាប់អនុវត្តក្នុងឆ្នាំ ២០២៤ ដើម្បីបន្តការគាំទ្រសកម្មភាពនៃអាជីវកម្មក្នុងស្រុក និងរក្សាចីរភាពកំណើនចំណូល ព្រមទាំងឆ្លើយតបនឹងបញ្ហាប្រឈម ដែលនឹងត្រូវអនុវត្តដោយអគ្គនាយកដ្ឋានពន្ធដារ រួមមាន÷

១. បន្តពង្រឹងការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ព្រមទាំងបន្តតាមដានការបំពេញកាតព្វកិច្ចសារពើពន្ធសម្រាប់រាល់សហគ្រាសដែលបានចុះបញ្ជីពន្ធដារ ក្នុងគោលដៅពង្រីកនូវមូលដ្ឋានពន្ធ តាមរយៈការពង្រឹងយន្តការចុះបញ្ជីសហគ្រាសថ្មី និងពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធ ក៏ដូចជាកាត់បន្ថយហានិភ័យពាក់ព័ន្ធនានា,

២. ដាក់ឱ្យអនុវត្តការប្រមូលចំណូលពន្ធលើចំណេញមូលធន,

៣. ពង្រឹងការប្រមូលចំណូលតាមវិស័យដែលនៅមានសក្តានុពល ដូចជា វិស័យសំណង់, វិស័យទូរគមនាគមន៍, វិស័យរ៉ែ, វិស័យផលិតស្រាបៀរ, ភេសជ្ជៈ និងថ្នាំជក់ ជាដើម,

៤. ពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពាក់ព័ន្ធនឹងអចលនទ្រព្យ ដោយធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យ, ពង្រឹងអនុលោមភាពនៃការបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់, និងពង្រឹងការបង់ពន្ធប្រថាប់ត្រាចំពោះការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាននានា,

៥. ពង្រឹងការប្រមូលចំណូលពន្ធ ជាពិសេសអាករលើតម្លៃបន្ថែម លើការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក,

៦. បន្តចូលរួមជាមួយស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ នៃច្រកចេញ-ចូលនៃប្រព័ន្ធអ៊ីនធឺណិតជាតិ (National Internet Gateway) និងប្រព័ន្ធទូទាត់ (Payment Gateway),

៧. បន្តកែលម្អ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវមុខងារស្នូលទាំង ៣ រួមមាន E-registration, E-filling, និង E-payment ដោយប្រើប្រាស់ថ្នាលបច្ចេកវិទ្យារួម ដែលមានភាពប្រឡាក់ក្រឡា, ស្វ័យប្រវត្តិកម្មពេញលេញ និង ផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ,

៨. បន្តដាក់អនុវត្តផែនការជាតិស្តីពីសវនកម្ម (National audit plan) ដើម្បីកំណត់អត្តសញ្ញាណជាយុទ្ធសាស្ត្រក្នុងការវិភាគហានិភ័យ និងពង្រឹងការធ្វើសវនកម្មដោយផ្អែកលើកម្រិតហានិភ័យ (Risk-Based Audit), និង

៩. ធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសដែលជំពាក់បំណុលពន្ធ និងពង្រឹងយន្តការតាមដាន និងតឹងទារបំណុលពន្ធ ។

**ខ. វិធានការផ្នែកគយ និងរដ្ឋាករ**

**៤៦.** វិធានការគន្លឹះ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តក្នុងឆ្នាំ ២០២៤ ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នឹងផ្តោតលើគោលដៅជាអាទិភាព ដូចខាងក្រោម ÷

១. បន្តអនុវត្តការលើកទឹកចិត្តពន្ធគយ និងពង្រឹងការអនុវត្តបទប្បញ្ញត្តិថ្មីៗ ស្របទៅនឹងការលើកទឹកចិត្តសម្រាប់វិស័យអាទិភាព ជាពិសេសសហគ្រាសធុនតូច និងមធ្យម,

២. បន្តពិនិត្យ និងកែលម្អគោលនយោបាយពន្ធ និងអាករ សម្រាប់វិស័យអាទិភាព និងមុខទំនិញនានា ឱ្យស្របតាមតម្រូវការចាំបាច់ និងការវិវត្តនៃមុខទំនិញទាំងនោះ,

៣. បន្តធ្វើសាមញ្ញកម្ម និងទំនើបកម្មនីតិវិធីគយ និងកិច្ចប្រតិបត្តិការគយផ្សេងទៀត ស្របតាមស្តង់ដារអន្តរជាតិ សំដៅបង្កើនគុណភាពនៃការផ្តល់សេវា និងភាពពេញចិត្តរបស់ធុរជន,

៤. បន្តការបញ្ជ្រាបចំណេះដឹងលើនីតិវិធីគយដល់ធុរជន ដោយផ្សព្វផ្សាយមគ្គុទ្ទេសក៍គិតពន្ធ, ចំណាត់ថ្នាក់ទំនិញ និងនីតិវិធីអនុគ្រោះពន្ធក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី,

៥. បន្តការលើកទឹកចិត្តធុរជន ដែលភ្ជាប់ជាមួយកម្មវិធីធុរជនល្អបំផុត (Best Trader) និងកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចបានទទួលការអនុញ្ញាត (Authorized Economic Operator Program),

៦. ជំរុញការអនុវត្តនីតិវិធី ដោយពង្រឹងការងារបង្ការ, ការងារបង្ក្រាបបទល្មើសគយ និងអនុវត្តតុលាការគយចំពោះបទល្មើសគយ ដែលមិនអាចសម្រុះសម្រួលដោយរដ្ឋបាលគយ,

៧. រៀបចំដាក់ឱ្យអនុវត្តប្រព័ន្ធកត់ត្រាកម្មសិទ្ធិបញ្ញា និងធ្វើទំនើបកម្មប្រព័ន្ធ ដើម្បីឱ្យស្របតាមស្តង់ដារអន្តរជាតិ ក្នុងការប្រកួតប្រជែងស្មើភាព, ការបំពេញបែបបទបញ្ចេញទំនិញ និងប្រព័ន្ធត្រួតពិនិត្យ,

៨. បន្តកែលម្អប្រសិទ្ធភាពការងារគ្រប់គ្រងហានិភ័យ តាមរយៈការកែលម្អវិធីសាស្ត្រ និងលក្ខណៈវិនិច្ឆ័យជ្រើសរើសសូចនាករហានិភ័យ,

៩. ពង្រីកវិសាលភាពនៃការអនុវត្តប្រព័ន្ធបញ្ចរតែមួយជាតិ ឈានទៅដំណាក់កាលទី ៣ និងតភ្ជាប់បញ្ចរតែមួយជាតិកម្ពុជាទៅនឹងបញ្ចរតែមួយអាស៊ាន, និង

១០. ពង្រឹងវិធានការអនុវត្ត និងសិក្សាលើការប្រមូលចំណូលលើទំនិញប្រណិត, ទំនិញប៉ះពាល់សុខភាព និងទំនិញប៉ះពាល់ដល់បរិស្ថាន ។

**គ. វិធានការផ្នែកចំណូលមិនមែនសារពើពន្ធ**

**៤៧.** ដើម្បីបន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ និងប្រមូលចំណូលពីប្រភពដែលមានសក្តានុពល, វិធានការគន្លឹះចាំបាច់ត្រូវបន្តអនុវត្ត រួមមាន÷

១. បន្តជំរុញការអនុវត្តច្បាប់, បទប្បញ្ញត្តិ, គោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងការគ្រប់គ្រង, ការប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ,

២. ជំរុញការរៀបចំឯកសារគោល (Blueprint) ស្តីពីការកែទម្រង់ប្រព័ន្ធចំណូលមិនមែនសារពើពន្ធ,

៣. ជំរុញការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងបញ្ជីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (SARMIS) នៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ,

៤. ត្រួតពិនិត្យលើការប្រមូលចំណូលសួយសារធនធានរ៉ែ ផ្អែកលើការកែសម្រួលអត្រាសួយសារលើតម្លៃផលិតផលរ៉ែ និងនីតិវិធីនៃការបង់ថ្លៃសួយសារ,

៥. បន្តតាមដាន, ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ការបង់ចំណូលសួយសារធនធានរ៉ែ ជាមួយនឹងបរិមាណធ្វើអាជីវកម្មជាក់ស្តែងរបស់ក្រុមហ៊ុន ដែលកំពុងប្រកបអាជីវកម្ម តាមរយៈក្រុមការងារអន្តរក្រសួង,

៦. ជំរុញការអនុវត្តការប្រមូលចំណូលពីឈ្នួលសម្បទានដីសេដ្ឋកិច្ច ដោយផ្អែកលើកិច្ចសន្យា និងគោលការណ៍គណនាថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ចឡើងវិញ,

៧. ពន្លឿនក្នុងការកែសម្រួលប្រកាសអន្តរក្រសួង អំពីការកំណត់ថ្លៃឈ្នួលដីឡើងវិញនៅតំបន់អាជ្ញាបណ្ណធនធានរ៉ែ,

៨. បន្តជំរុញការអនុវត្តការបង់ចំណូលពីសម្បទានដីសេដ្ឋកិច្ច និងធនធានរ៉ែ តាមរយៈប្រព័ន្ធបង់ប្រាក់អេឡិចត្រូនិក និងបង់ប្រាក់រំដោះឱ្យបានទៀងទាត់ ដោយមានការធ្វើអធិការកិច្ច ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,

៩. បន្តតាមដាន និងគ្រប់គ្រងចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ តាមរយៈកិច្ចសន្យាជួល និងការគណនាតម្លៃជួលថ្មីផ្អែកតាមតម្លៃគិតពន្ធប្រថាប់ត្រាផ្ទេរអចលនទ្រព្យ,

១០. ដកហូតមកវិញនូវចំនួនប្រេកង់ដែលមិនប្រើប្រាស់ និងរៀបចំដាក់ដេញថ្លៃឡើងវិញ ដើម្បីកៀរគរចំណូលបន្ថែម,

១១. បន្តពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពី វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីរក្សាឱ្យបាននូវស្ថិរភាពចំណូល,

១២. បន្តរៀបចំយន្តការទប់ស្កាត់កុំឱ្យមានបំណុលថ្មី និងពង្រឹងការតឹងទារបំណុល តាមរយៈគណៈកម្មការអន្តរក្រសួង, និង

១៣. បន្តពិនិត្យ និងពិភាក្សាលើការកៀរគរប្រភពចំណូលមិនមែនសារពើពន្ធថ្មី ។

### ៤.២ ទិសដៅគោលនយោបាយចំណាយ

**៤៨.** ដើម្បីសម្រេចឱ្យបាននូវគោលដៅរក្សាស្ថិរភាពសង្គម និងទ្រទ្រង់ការងើបឡើងវិញនូវកំណើនសេដ្ឋកិច្ច, រាជរដ្ឋាភិបាលចាំបាច់ត្រូវពង្រឹងប្រសិទ្ធភាពថវិកា ទាំងកម្រិតវិភាជន៍ ព្រមទាំងប្រតិបត្តិការ និងការឆ្លើយតបទៅនឹងទិសដៅគោលនយោបាយ និងកម្មវិធីកែទម្រង់នានា តាមរយៈវិធានការសំខាន់ៗ ដូចខាងក្រោម÷

១. បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ក្នុងគោលដៅលើកកម្ពស់ជីវភាពរស់នៅ, បង្កើនផលិតភាពការងារ និង ពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍សមធម៌, គុណាធិបតេយ្យ និងចីរភាពថវិកា,

២. កំណត់គោលការណ៍ក្នុងការជ្រើសរើសមន្ត្រីក្របខណ្ឌថ្មី សម្រាប់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដែលត្រូវសមាមាត្រនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ លើកលែងតែក្រសួងអាទិភាព,

៣. បន្តតម្រង់ធនធានថវិកាសម្រាប់វិស័យគន្លឹះ ដែលនឹងធានាឱ្យបាននូវភាពធន់រឹងមាំប្រកបដោយបរិយាបន្ន និងចីរភាព តាមរយៈការផ្តល់អាទិភាពទៅលើការពង្រឹងរដ្ឋបាលសាធារណៈ, ការអភិវឌ្ឍមូលធនមនុស្ស, ការកសាងហេដ្ឋារចនាសម្ព័ន្ធទាំងរូបវន្ត និងឌីជីថល, ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធសុខាភិបាល,

៤. បន្តកែលម្អគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃផែនការយុទ្ធសាស្ត្រថវិកា ដោយពង្រឹងការផ្សារភ្ជាប់ថវិកា ទៅនឹងគោលនយោបាយតាមវិស័យអាទិភាព និងបន្តពង្រឹងការផ្សារភ្ជាប់ផែនការលទ្ធកម្មជាមួយនឹងសំណើថវិកាប្រចាំឆ្នាំ,

៥. បន្តអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ សំដៅធានាបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ ដោយផ្តោតសំខាន់លើការវិនិយោគចំពោះវិស័យអាទិភាព ជាពិសេស វិស័យបង្កើនផលិតភាព, ជំរុញការតភ្ជាប់ និង លើកកម្ពស់សមត្ថភាពប្រកួតប្រជែង, និង

៦. បន្តជំរុញការអនុវត្តកម្មវិធីកែទម្រង់នានា និងគោលនយោបាយអាទិភាព ដែលរួមមាន ការពង្រឹង ក). ការរៀបចំក្របខណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៤-២០២៦, ខ). ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥, គ). ការអនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥, ឃ). ការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០២៤-២០២៨, ង). ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ ២០១៩-២០២៥ និង ច). ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ ២០១៩-២០២៥ ។

## ៥. សេចក្តីសន្និដ្ឋាន

**៤៩.** ជារួម, ទស្សនវិស័យសេដ្ឋកិច្ចសកលសម្រាប់ឆ្នាំ ២០២៤ ត្រូវបានរំពឹងថានឹងសម្រេចបានកំណើនល្អជាមួយនឹងការថមថយអត្រាអតិផរណា ខណៈដែលឆ្នាំ ២០២៣ ជាចំណុចរបត់មួយ ដែលកំណើនសេដ្ឋកិច្ចសកល

ធ្លាក់ចុះដល់កម្រិតទាបបំផុត ក្នុងបរិការណ៍ក្រោយវិបត្តិជំងឺកូវីដ-១៩ ។ ឈរលើមូលដ្ឋាននេះ, កំណើនសេដ្ឋកិច្ចជាតិក្នុងឆ្នាំ ២០២៤ រំពឹងថានឹងសម្រេចបានក្នុងអត្រា **៦,៦%** ជាមួយនឹងអត្រាអតិផរណាស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបានក្នុងអត្រា ២,៥% និងការរក្សាបាននូវស្ថិរភាពអត្រាប្តូរប្រាក់ ៤ ០៦៥ រៀលក្នុងមួយដុល្លារអាមេរិក ។ កំណើនខ្ពស់ និងរឹងមាំ នេះ គាំទ្រដោយលទ្ធភាពក្នុងការសម្របខ្លួនបានទៅនឹងនិន្នាការសកល និងតំបន់ ដែលបាននិងកំពុងលេចឡើង, ការត្រៀមខ្លួនដោះស្រាយបញ្ហាប្រឈម និងហានិភ័យធំៗ, ការទាក់ទាញវិនិយោគដែលមានតម្លៃបន្ថែមខ្ពស់, ភាព-អំណោយផលនៃទីតាំងភូមិសាស្ត្រ និងភាគលាភប្រជាសាស្ត្រកម្ពុជា, ការទាញប្រយោជន៍ពីការរីកចម្រើនយ៉ាងរហ័សនៃឌីជីថលូបនីយកម្ម, ព្រមទាំងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងពហុភាគីនានា ។

**៥០.** ផ្អែកលើទស្សនវិស័យសេដ្ឋកិច្ចខាងលើ, ក្របខណ្ឌចំណូល-ចំណាយឆ្នាំ ២០២៤ ត្រូវបានរៀបចំប្រកបដោយភាពប្រយ័ត្នប្រយែងខ្ពស់ ដោយឱនភាពថវិកានឹងស្ថិតក្នុងរង្វង់ -៣,២២% នៃ ផសស ក្នុងគោលដៅធានានូវភាពរឹងមាំ និងចីរភាពហិរញ្ញវត្ថុសាធារណៈ ។ ជាពិសេស, ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងបន្តឈរលើគោលការណ៍÷ (១). ការពង្រឹងវិន័យ និងបង្កើនប្រសិទ្ធភាពថវិកា ទាំងកម្រិតវិភាជន៍ និងប្រតិបត្តិការ ពោលគឺការចាយវាយឱ្យចំទិសដៅ ហើយផ្តោតលើតម្លៃនៃលុយ, (២). ការកែលម្អអភិបាលកិច្ច និងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងការប្រមូលចំណូល, ការបន្តធ្វើទំនើបកម្មប្រព័ន្ធចំណូល និងការផ្តល់សេវាសាធារណៈប្រកបដោយវិជ្ជាជីវៈ, និង (៣). ការកៀរគរលើប្រភពចំណូលដែលមានសក្តានុពល ។

**៥១.** រាជរដ្ឋាភិបាល នឹងខិតខំពន្លឿនកម្មវិធីកែទម្រង់សំខាន់ៗ និងដាក់ចេញវិធានការកែទម្រង់មុតស្រួចបន្ថែមព្រមទាំងវិធានការគាំទ្រជាបន្តបន្ទាប់តាមតម្រូវការជាក់ស្តែង សំដៅស្តារ និងជំរុញកំណើនសេដ្ឋកិច្ចជាតិឡើងវិញឱ្យបានឆាប់រហ័ស ដើម្បីលើកកម្ពស់ និងជំរុញវិស័យឯកជន ទាំងក្នុងសកម្មភាពធុរកិច្ច, ពាណិជ្ជកម្ម និងវិនិយោគ ក្នុងការចាប់យកកាលានុវត្តភាពថ្មីៗ ដែលកើតចេញពីការប្រែប្រួលនិន្នាការនានា ជាពិសេស ការផ្លាស់ប្តូរ និងការធ្វើពិពិធកម្មខ្សែច្រវាក់ផលិតកម្មតំបន់ និងសកល, និងការកើនឡើងនូវការប្រើប្រាស់បច្ចេកវិទ្យាជឿនលឿន និងបច្ចេកវិទ្យាឌីជីថលទាំងក្នុងក្របខណ្ឌប្រទេស, តំបន់ និងសកល ។ ក្នុងបរិការណ៍ដែលឆ្នាំ ២០២៤ ជាឆ្នាំដំបូងនៃអាណត្តិរបស់រាជរដ្ឋា-ភិបាល នីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាលនឹងបន្តប្រកាន់ខ្ជាប់នូវការអនុវត្តគោលការណ៍ “**រក្សាសមិទ្ធផលចាស់ បង្កើតសមិទ្ធផលថ្មី**” សំដៅលើកកម្ពស់ការបន្តអភិវឌ្ឍជាតិប្រកបដោយបរិយាបន្ន, ភាពធន់ និងចីរភាព, ជាពិសេសរក្សាឱ្យបាននូវសង្គមជាតិដែលប្រជាពលរដ្ឋយើងរស់នៅក្នុងបរិយាកាសមួយប្រកបដោយវិបុលភាព និងភាពសុខដុម ។

❋❋❋✧❋❋❋



Telegram: t.me/economyfinance

**ឧបសម្ព័ន្ធទី១៖ ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច (២០២០-២០២៦)**

| **សូចនាករម៉ាក្រូសេដ្ឋកិច្ច** | **2020** | **2021** | **2022** | **2023 ប.** | **2024 ព្យ.** | **2025 ព្យ.** | **2026 ព្យ.** |
|---|---|---|---|---|---|---|---|
| ផសស ថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | **105,892** | **110,506** | **120,989** | **130,805** | **142,957** | **156,613** | **172,144** |
| ផសស សម្រាប់មនុស្សម្នាក់ (ដុល្លារអាម៉េរិក) | 1,605 | 1,659 | 1,784 | 1,917 | 2,071 | 2,233 | 2,427 |
| កំណើន ផសស ពិត (%) | **-3.1%** | **3.0%** | **5.2%** | **5.6%** | **6.6%** | **6.9%** | **7.2%** |
| អត្រាបរិត្តផរណា ផសស (កំណើនប្រចាំឆ្នាំ) | -0.7% | 1.3% | 4.1% | 2.4% | 2.5% | 2.5% | 2.5% |
| អត្រាអតិផរណា (កំណើនជាមធ្យមប្រចាំឆ្នាំ) | **2.9%** | **2.9%** | **5.3%** | **2.5%** | **2.5%** | **2.5%** | **2.5%** |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លារអាម៉េរិក) | 4,080 | 4,068 | 4,090 | 4,065 | 4,065 | 4,065 | 4,065 |
| ការនាំចេញ (% នៃ ផសស) | 71.4% | 71.9% | 78.4% | 77.7% | 82.9% | 87.3% | 91.5% |
| ការនាំចូល (% នៃ ផសស) | -81.2% | -113.1% | -108.2% | -96.6% | -100.7% | -104.4% | -107.7% |
| សមតុល្យពាណិជ្ជកម្ម (% នៃ ផសស) | -9.8% | -41.4% | -29.8% | -18.8% | -17.7% | -17.1% | -16.2% |
| សមតុល្យគណនីចរន្ត (រួមបញ្ចូលបង្វែរ) (% នៃ ផសស) | **-3.4%** | **-40.1%** | **-25.6%** | **-10.7%** | **-9.6%** | **-8.6%** | **-7.6%** |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាម៉េរិក) | **21,334** | **20,265** | **17,805** | **19,437** | **21,285** | **23,186** | **25,768** |
| ចំនួនខែនៃការនាំចូល | 13.4 | 7.4 | 6.1 | 6.9 | 6.6 | 6.4 | 6.2 |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា (វិស័យខាងក្រៅ ឆ្នាំ ២០២២) និងការប៉ាន់ស្មាន និងការព្យាករបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ខែ ឧសភា ឆ្នាំ ២០២៣ ។

## ឧបសម្ព័ន្ធ ២ : ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ

### ក. ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ២០២២-២០២៤

ផសស តាមថ្លៃចរន្តឆ្នាំ ២០២២ (បណ្ដោះអាសន្ន) 120,989

ផសស តាមថ្លៃចរន្តឆ្នាំ ២០២៣ (ប៉ាន់ស្មាន) 130,805

ផសស តាមថ្លៃចរន្តឆ្នាំ ២០២៤ (គម្រោង) 142,957

ឯកតា៖ ប៊ីលានរៀល

| ចំណូល-ចំណាយ | ២០២២ | | | | | ២០២៣ | | | | | ២០២៤ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ | បណ្ដោះ អាសន្ន (*) | បណ្ដោះ. %២០២២ច្បា. | បណ្ដោះ. %២០២១ | បណ្ដោះ. %ផសស | ច្បាប់ | កែតម្រូវ | កែ. %២០២៣ច្បា. | កែ. %២០២២ប. | កែ. %ផសស | គម្រោង | %២០២៣កែ. | %២០២៣ច្បា | %ផសស |
| **ចំណូលសរុប** | 32,676 | 35,226 | 107.8% | 120.6% | 29.12% | 36,768 | 37,151 | 101.0% | 105.5% | 28.40% | 32,976 | 88.8% | 89.7% | 23.07% |
| ចំណូលមូលធន/ចំណូលផ្សេងៗ ក្រៅប្រទេស (**) | 7,082 | 7,284 | 102.9% | 114.1% | 6.02% | 7,456 | 7,456 | 100.0% | 102.4% | 5.70% | 696 | 9.3% | 9.3% | 0.49% |
| **ចំណូលក្នុងប្រទេសសរុប** | 25,594 | 27,942 | 109.2% | 122.4% | 23.09% | 29,312 | 29,695 | 101.3% | 106.3% | 22.70% | 32,280 | 108.7% | 110.1% | 22.58% |
| ចំណូលចរន្ត | 24,289 | 27,826 | 114.6% | 122.2% | 23.00% | 28,167 | 28,550 | 101.4% | 102.6% | 21.83% | 31,916 | 111.8% | 113.3% | 22.33% |
| ចំណូលមូលធន/ចំណូលផ្សេងៗ ក្នុងប្រទេស (***) | 1,305 | 116 | 8.9% | 204.0% | 0.10% | 1,145 | 1,145 | 100.0% | 986.6% | 0.88% | 363 | 31.7% | 31.7% | 0.25% |
| **រដ្ឋបាលកណ្ដាល** | | | | | | | | | | | | | | |
| **ចំណូលចរន្ត** | 22,157 | 25,173 | 113.6% | 123.0% | 20.81% | 25,564 | 26,108 | 102.1% | 103.7% | 19.96% | 29,242 | 112.0% | 114.4% | 20.46% |
| ចំណូលសារពើពន្ធ | 20,227 | 22,897 | 113.2% | 123.8% | 18.93% | 23,422 | 23,224 | 99.2% | 101.4% | 17.75% | 25,759 | 110.9% | 110.0% | 18.02% |
| ចំណូលមិនមែនសារពើពន្ធ | 1,930 | 2,275 | 117.9% | 115.5% | 1.88% | 2,143 | 2,883 | 134.6% | 126.7% | 2.20% | 3,483 | 120.8% | 162.6% | 2.44% |
| **ចំណូលមូលធន/ចំណូលផ្សេងៗសរុប** | 8,387 | 7,400 | 88.2% | 114.9% | 6.12% | 8,601 | 8,601 | 100.0% | 116.2% | 6.58% | 1,060 | 12.3% | 12.3% | 0.74% |
| **ថ្នាក់ក្រោមជាតិ** | | | | | | | | | | | | | | |
| **ចំណូលចរន្ត** | 2,132 | 2,653 | 124.5% | 115.3% | 2.19% | 2,603 | 2,443 | 93.9% | 92.1% | 1.87% | 2,674 | 109.5% | 102.8% | 1.87% |
| ចំណូលសារពើពន្ធ | 1,584 | 2,051 | 129.5% | 114.6% | 1.70% | 2,172 | 1,979 | 91.1% | 96.5% | 1.51% | 2,215 | 111.9% | 102.0% | 1.55% |
| ចំណូលមិនមែនសារពើពន្ធ | 548 | 602 | 109.9% | 117.8% | 0.50% | 430 | 464 | 107.8% | 77.0% | 0.35% | 460 | 99.2% | 106.9% | 0.32% |
| **ចំណូលតាមអង្គភាព** | | | | | | | | | | | | | | |
| អគ្គនាយកដ្ឋានពន្ធដារ | 11,411 | 13,984 | 122.5% | 125.5% | 11.56% | 14,457 | 15,180 | 105.0% | 108.6% | 11.61% | 16,856 | 111.0% | 116.6% | 11.79% |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 10,400 | 10,965 | 105.4% | 120.0% | 9.06% | 11,137 | 10,023 | 90.0% | 91.4% | 7.66% | 11,118 | 110.9% | 99.8% | 7.78% |
| អគ្គនាយកដ្ឋានចំណូលផ្សេងៗ | 2,478 | 2,877 | 116.1% | 115.9% | 2.38% | 2,573 | 3,347 | 130.1% | 116.3% | 2.56% | 3,943 | 117.8% | 153.3% | 2.76% |

| ចំណូល-ចំណាយ | ២០២២ ច្បាប់ | ២០២២ បណ្ដោះអាសន្ន (*) | ២០២២ បណ្ដោះ. %២០២២ច្បា. | ២០២២ បណ្ដោះ. %២០២១ | ២០២២ បណ្ដោះ. %ផសស | ២០២៣ ច្បាប់ | ២០២៣ កែតម្រូវ | ២០២៣ កែ. %២០២៣ច្បា. | ២០២៣ កែ. %២០២២ប. | ២០២៣ កែ. %ផសស | ២០២៤ គ្រោង | ២០២៤ %២០២៣កែ. | ២០២៤ %២០២៣ច្បា | ២០២៤ %ផសស |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ចំណាយសរុប** | **34,709** | **32,469** | **93.5%** | **95.0%** | **26.84%** | **39,206** | **38,747** | **98.8%** | **119.3%** | **29.62%** | **37,577** | **97.0%** | **95.8%** | **26.29%** |
| ចំណាយចរន្ត | 20,850 | 20,097 | 96.4% | 94.4% | 16.61% | 22,929 | 22,469 | 98.0% | 111.8% | 17.18% | 26,351 | 117.3% | 114.9% | 18.43% |
| ចំណាយមូលធន | 13,858 | 12,372 | 89.3% | 96.1% | 10.23% | 16,277 | 16,277 | 100.0% | 131.6% | 12.44% | 11,226 | 69.0% | 69.0% | 7.85% |
| **រដ្ឋបាលកណ្ដាល** | | | | | | | | | | | | | | |
| **ចំណាយចរន្ត** | **19,112** | **17,914** | **93.7%** | **91.9%** | **14.81%** | **20,839** | **20,539** | **98.6%** | **114.7%** | **15.70%** | **24,211** | **117.9%** | **116.2%** | **16.94%** |
| **ចំណាយមូលធន** | **11,988** | **10,541** | **87.9%** | **93.2%** | **8.71%** | **13,904** | **13,904** | **100.0%** | **131.9%** | **10.63%** | **10,692** | **76.9%** | **76.9%** | **7.48%** |
| -ដោយហិរញ្ញប្បទានក្នុងប្រទេស | 6,174 | 4,975 | 80.6% | 83.0% | 4.11% | 7,731 | 7,731 | 100.0% | 155.4% | 5.91% | 4,484 | 58.0% | 58.0% | 3.14% |
| -ដោយហិរញ្ញប្បទានក្រៅប្រទេស | 5,813 | 5,566 | 95.7% | 104.8% | 4.60% | 6,173 | 6,173 | 100.0% | 110.9% | 4.72% | 6,208 | 100.6% | 100.6% | 4.34% |
| **ថ្នាក់ក្រោមជាតិ** | | | | | | | | | | | | | | |
| ចំណាយចរន្ត | 3,002 | 3,447 | 114.8% | 119.8% | 2.85% | 3,549 | 3,389 | 95.5% | 98.3% | 2.59% | 3,699 | 109.1% | 104.2% | 2.59% |
| ចំណាយមូលធន | 393 | 393 | 100.0% | 101.2% | 0.32% | 513 | 513 | 100.0% | 130.5% | 0.39% | 535 | 104.3% | 104.3% | 0.37% |
| **ឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ** | 1,263 | 1,264 | 100.1% | 117.9% | 1.05% | 1,459 | 1,459 | 100.0% | 115.4% | 1.12% | 1,559 | 106.9% | 106.9% | 1.09% |
| **អតិរេកថវិកាចរន្ត** | 3,439 | 7,729 | 224.8% | 525.9% | 6.39% | 5,238 | 6,081 | 116.1% | 78.7% | 4.65% | 5,566 | 91.5% | 106.3% | 3.89% |
| **តម្រូវការហិរញ្ញប្បទាន** | **9,114** | **4,527** | **49.7%** | **39.9%** | **3.74%** | **9,894** | **9,051** | **91.5%** | **199.9%** | **6.92%** | **6,716** | **74.2%** | **67.9%** | **4.70%** |
| ការទូទាត់ការខ្ចី (****) | | | | | | | | | | | 2,115 | | | 1.48% |
| ឱនភាពសរុប (*****) | 9,114 | 4,527 | 49.7% | 39.9% | 3.74% | 9,894 | 9,051 | 91.5% | 199.9% | 6.92% | 4,601 | 50.8% | 46.5% | 3.22% |
| **ប្រភពហិរញ្ញប្បទាន** | **9,114** | **4,527** | **49.7%** | **39.9%** | **3.74%** | **9,894** | **9,051** | **91.5%** | **199.9%** | **6.92%** | **6,716** | **74.2%** | **67.9%** | **4.70%** |
| **- ហិរញ្ញប្បទាន ក្រៅប្រទេស** | **7,082** | **7,284** | **102.9%** | **114.1%** | **6.02%** | **7,456** | **7,456** | **100.0%** | **102.4%** | **5.70%** | **6,276** | **84.2%** | **84.2%** | **4.39%** |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 5,813 | 5,566 | 95.7% | 104.8% | 4.60% | 6,173 | 6,173 | 100.0% | 110.9% | 4.72% | 5,579 | 90.4% | 90.4% | 3.90% |
| មូលនិធិទ្រទ្រង់ថវិកា | 1,268 | 1,718 | 135.5% | 160.3% | 1.42% | 1,283 | 1,283 | 100.0% | 74.7% | 0.98% | 697 | 54.3% | 54.3% | 0.49% |
| **- ហិរញ្ញប្បទាន ក្នុងប្រទេស** | **2,033** | **(2,757)** | **-135.6%** | **-55.5%** | **-2.28%** | **2,439** | **1,595** | **65.4%** | **-57.9%** | **1.22%** | **440** | **27.6%** | **18.0%** | **0.31%** |
| ការបោះផ្សាយមូលបត្ររដ្ឋ | | | | | | | | | | | 440 | | | 0.31% |
| ប្រាក់បញ្ញើរាជរដ្ឋាភិបាល ((+) ប្រើប្រាស់/ (-) សន្សំ) | 2,033 | (2,757) | -135.6% | -55.5% | -2.28% | 2,439 | 1,595 | 65.4% | -57.9% | 1.22% | - | 0.0% | 0.0% | 0.00% |

*សម្គាល់ ÷*

*(*) ទិន្នន័យប្រព័ន្ធ FMIS ត្រឹមថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០២៣ សម្រាប់ចំណូលប្រមូលដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងចំណូលមិនមែនសារពើពន្ធ និងប្រើប្រាស់ទិន្នន័យអនឡាញសម្រាប់ ចំណូលប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ*

*(**) ចំណូលមូលធន/ចំណូលផ្សេងៗក្រៅប្រទេស ចាប់ពីឆ្នាំ ២០២៤ គិតបញ្ចូលតែហិរញ្ញប្បទាន ឥតសំណងពីក្រៅប្រទេសប៉ុណ្ណោះ*

*(***) ចំណូលមូលធន/ចំណូលផ្សេងៗក្នុងប្រទេស ចាប់ពីឆ្នាំ ២០២៤ ពុំគិតបញ្ចូលចំណូលពីការបោះផ្សាយមូលបត្ររដ្ឋទៀតទេ*

*(****) ការទូទាត់ការខ្ចី ចាប់ពីឆ្នាំ ២០២៤ ពុំត្រូវបានកត់ត្រាជាចំណាយមូលធនទៀតនោះទេ ប៉ុន្តែត្រូវបានកត់ត្រាជាតម្រូវការហិរញ្ញប្បទាន*

*(*****) ឱនភាពសរុប ចាប់ពីឆ្នាំ ២០២៤ ត្រូវបានគណនាដោយ ចំណូលសរុប ដកនឹង ចំណាយសរុប*

## ខ. ក្របខណ្ឌចំណូល-ចំណាយរយៈពេលមធ្យម ២០២៣-២០២៦

| ប៊ីលានរៀល | 2022 ប. (*) | 2023 ច្បា. | 2023 កែ. | 2024 ព្យ. | 2025 ព្យ. | 2026 ព្យ. |
|---|---|---|---|---|---|---|
| <u>ចំណាយ បន្ទុកបុគ្គលិកជា %នៃ ចំណាយចរន្តសរុប</u> | <u>47.7%</u> | <u>45.5%</u> | <u>46.4%</u> | <u>41.8%</u> | <u>39.5%</u> | <u>38.5%</u> |
| **I ចំណូលសរុប** | **35,226** | **36,768** | **37,151** | **32,976** | **37,490** | **42,190** |
| **I.1 ចំណូលមូលធន/ចំណូលផ្សេងៗ ក្រៅប្រទេស (**)** | **7,284** | **7,456** | **7,456** | **696** | **631** | **534** |
| **I.2 ចំណូលក្នុងស្រុក** | **27,942** | **29,312** | **29,695** | **32,280** | **36,858** | **41,656** |
| *ចំណូលចរន្តសរុប* | *27,826* | *28,167* | *28,550* | *31,916* | *36,385* | *41,179* |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 10,965 | 11,137 | 10,023 | 11,118 | 12,512 | 14,084 |
| អគ្គនាយកដ្ឋានពន្ធដារ | 13,984 | 14,457 | 15,180 | 16,856 | 19,473 | 22,049 |
| ចំណូលមិនមែនសារពើពន្ធសរុប | 2,877 | 2,573 | 3,347 | 3,943 | 4,400 | 5,046 |
| *ចំណូលមូលធន/ចំណូលផ្សេងៗ ក្នុងប្រទេស (***)* | *116* | *1,145* | *1,145* | *363* | *473* | *478* |
| **II. ចំណាយសរុប** | **32,469** | **39,206** | **38,747** | **37,577** | **42,324** | **46,533** |
| **II.1 ចំណាយចរន្តសរុប** | **20,097** | **22,929** | **22,469** | **26,351** | **29,482** | **32,073** |
| បន្ទុកបុគ្គលិក | 9,592 | 10,435 | 10,435 | 11,009 | 11,637 | 12,346 |
| បន្ទុកមិនមែនបុគ្គលិក | 10,505 | 12,494 | 12,034 | 15,342 | 17,845 | 19,726 |
| **II.2 ចំណាយមូលធនសរុប** | **12,372** | **16,277** | **16,277** | **11,226** | **12,842** | **14,460** |
| ហិរញ្ញប្បទាន ក្នុងប្រទេសសរុប | 5,368 | 8,244 | 8,244 | 5,019 | 6,473 | 7,690 |
| ការទូទាត់ប្រាក់កម្ចី (****) | 1,438 | 1,860 | 1,860 | - | - | - |
| ហិរញ្ញប្បទាន ក្រៅប្រទេស | 5,566 | 6,173 | 6,173 | 6,208 | 6,370 | 6,770 |
| **III. អតិរេកចរន្ត** | **7,729** | **5,238** | **6,081** | **5,566** | **6,903** | **9,106** |
| **IV. ឱនភាព/អតិរេកសរុប (*****)** | **(4,527)** | **(9,894)** | **(9,051)** | **(4,601)** | **(4,834)** | **(4,343)** |
| **កំណើនប្រចាំឆ្នាំ** | **2022ប./ 2021** | **2023ច្បា./ 2022ប.** | **2023កែ./ 2022ប.** | **2024ព្យ.** | **2025ព្យ.** | **2026ព្យ.** |
| **I ចំណូលសរុប** | **20.6%** | **4.4%** | **5.5%** | **-11.2%** | **13.7%** | **12.5%** |
| **I.1 ចំណូលមូលធន/ចំណូលផ្សេងៗ ក្រៅប្រទេស (**)** | **14.1%** | **2.4%** | **2.4%** | **-90.7%** | **-9.3%** | **-15.5%** |
| **I.2 ចំណូលក្នុងស្រុក** | **22.4%** | **4.9%** | **6.3%** | **8.7%** | **14.2%** | **13.0%** |
| *ចំណូលចរន្តសរុប* | *22.2%* | *1.2%* | *2.6%* | *11.8%* | *14.0%* | *13.2%* |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 20.0% | 1.6% | -8.6% | 10.9% | 12.5% | 12.6% |
| អគ្គនាយកដ្ឋានពន្ធដារ | 25.5% | 3.4% | 8.6% | 11.0% | 15.5% | 13.2% |
| ចំណូលមិនមែនសារពើពន្ធសរុប | 15.9% | -10.6% | 16.3% | 17.8% | 11.6% | 14.7% |
| *ចំណូលមូលធន/ចំណូលផ្សេងៗ ក្នុងប្រទេស (***)* | *104.0%* | *886.6%* | *886.6%* | *-68.3%* | *30.2%* | *1.0%* |
| **II. ចំណាយសរុប** | **-5.0%** | **20.7%** | **19.3%** | **-3.0%** | **12.6%** | **9.9%** |
| **II.1 ចំណាយចរន្តសរុប** | **-5.6%** | **14.1%** | **11.8%** | **17.3%** | **11.9%** | **8.8%** |
| បន្ទុកបុគ្គលិក | 3.8% | 8.8% | 8.8% | 5.5% | 5.7% | 6.1% |
| បន្ទុកមិនមែនបុគ្គលិក | -12.9% | 18.9% | 14.6% | 27.5% | 16.3% | 10.5% |
| **II.2 ចំណាយមូលធនសរុប** | **-3.9%** | **31.6%** | **31.6%** | **-31.0%** | **14.4%** | **12.6%** |
| ហិរញ្ញប្បទាន ក្នុងប្រទេសសរុប | *-15.9%* | *53.6%* | *53.6%* | *-39.1%* | *29.0%* | *18.8%* |
| ការទូទាត់ប្រាក់កម្ចី (****) | 21.5% | 29.3% | 29.3% | -100.0% | | |
| ហិរញ្ញប្បទាន ក្រៅប្រទេស | 4.8% | 10.9% | 10.9% | 0.6% | 2.6% | 6.3% |

| ផលធៀបនឹងផ.ស.ស | 2022 បណ្ដោះ. | 202៣ ច្ប. | 202៣ កែ. | 202៤ ព្យ. | 202៥ ព្យ. | 202៦ ព្យ. |
|---|---|---|---|---|---|---|
| **I ចំណូលសរុប** | **29.12%** | **28.11%** | **28.40%** | **23.07%** | **23.94%** | **24.51%** |
| **I.1 ចំណូលមូលធន/ចំណូលផ្សេងៗ ក្រៅប្រទេស (**)** | **6.02%** | **5.70%** | **5.70%** | **0.49%** | **0.40%** | **0.31%** |
| **I.2 ចំណូលក្នុងស្រុក** | **23.09%** | **22.41%** | **22.70%** | **22.58%** | **23.53%** | **24.20%** |
| *ចំណូលចរន្តសរុប* | *23.00%* | *21.53%* | *21.83%* | *22.33%* | *23.23%* | *23.92%* |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 9.06% | 8.51% | 7.66% | 7.78% | 7.99% | 8.18% |
| អគ្គនាយកដ្ឋានពន្ធដារ | 11.56% | 11.05% | 11.61% | 11.79% | 12.43% | 12.81% |
| ចំណូលមិនមែនសារពើពន្ធសរុប | 2.38% | 1.97% | 2.56% | 2.76% | 2.81% | 2.93% |
| *ចំណូលមូលធន/ចំណូលផ្សេងៗ ក្នុងប្រទេស (***)* | *0.10%* | *0.88%* | *0.88%* | *0.25%* | *0.30%* | *0.28%* |
| **II. ចំណាយសរុប** | **26.84%** | **29.97%** | **29.62%** | **26.29%** | **27.02%** | **27.03%** |
| **II.1 ចំណាយចរន្តសរុប** | **16.61%** | **17.53%** | **17.18%** | **18.43%** | **18.82%** | **18.63%** |
| បន្ទុកបុគ្គលិក | 7.93% | 7.98% | 7.98% | 7.70% | 7.43% | 7.17% |
| បន្ទុកមិនមែនបុគ្គលិក | 8.68% | 9.55% | 9.20% | 10.73% | 11.39% | 11.46% |
| **II.2 ចំណាយមូលធនសរុប** | **10.23%** | **12.44%** | **12.44%** | **7.85%** | **8.20%** | **8.40%** |
| ហិរញ្ញប្បទាន ក្នុងប្រទេសសរុប | *4.44%* | *6.30%* | *6.30%* | *3.51%* | *4.13%* | *4.47%* |
| ការទូទាត់ប្រាក់កម្ចី (****) | 1.19% | 1.42% | 1.42% | 0.00% | 0.00% | 0.00% |
| ហិរញ្ញប្បទាន ក្រៅប្រទេស | 4.60% | 4.72% | 4.72% | 4.34% | 4.07% | 3.93% |
| **III. អតិរេកចរន្ត** | **6.39%** | **4.00%** | **4.65%** | **3.89%** | **4.41%** | **5.29%** |
| **IV.ឱនភាព/អតិរេកសរុប (*****)** | **-3.74%** | **-7.56%** | **-6.92%** | **-3.22%** | **-3.09%** | **-2.52%** |

*សម្គាល់ ÷*

*(*) ទិន្នន័យប្រព័ន្ធ FMIS ត្រឹមថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០២៣ សម្រាប់ចំណូលប្រមូលដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងចំណូលមិនមែនសារពើពន្ធ និងប្រើប្រាស់ទិន្នន័យអនឡាញសម្រាប់ ចំណូលប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ*

*(**) ចំណូលមូលធន/ចំណូលផ្សេងៗ ក្រៅប្រទេស ចាប់ពីឆ្នាំ ២០២៤ គិតបញ្ចូលតែហិរញ្ញប្បទានឥតសំណងពីក្រៅប្រទេសប៉ុណ្ណោះ*

*(***) ចំណូលមូលធន/ចំណូលផ្សេងៗ ក្នុងប្រទេស ចាប់ពីឆ្នាំ ២០២៤ ពុំគិតបញ្ចូលចំណូលពីការបោះផ្សាយមូលបត្ររដ្ឋទៀតទេ*

*(****) ការទូទាត់ការខ្ចី ចាប់ពីឆ្នាំ ២០២៤ ពុំត្រូវបានកត់ត្រាជាចំណាយមូលធនទៀតនោះទេ*

*(*****) ឱនភាពសរុប ចាប់ពីឆ្នាំ ២០២៤ ត្រូវបានគណនាដោយ ចំណូលសរុប ដកនឹង ចំណាយសរុប*

## គ. ចំណាយតាមវិស័យរយៈពេលមធ្យម ២០២៣-២០២៦

| ចំណាយតាមវិស័យ (ប៊ីលានរៀល) | 2023 ច្ប. | 2023 ប៉ាន់. | 2024 គ្រ. | 2025 គ្រ. | 2026 គ្រ. |
|---|---|---|---|---|---|
| **1. ចំណាយសរុបតាមវិស័យ** | **39,206** | **38,747** | **37,577** | **42,324** | **46,533** |
| **1.1 ចំណាយថ្នាក់ជាតិ** | **36,604** | **36,304** | **34,903** | **39,454** | **43,321** |
| **ក.វិស័យរដ្ឋបាលទូទៅ** | **3,079** | **3,656** | **2,843** | **3,111** | **3,325** |
| ចំណាយចរន្ត | 2,841 | 3,417 | 2,657 | 2,920 | 3,122 |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *762* | *762* | *794* | *823* | *859* |
| ចំណាយមូលធន | 238 | 238 | 186 | 191 | 203 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | - | - | - | - | - |
| **ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់** | **5,216** | **5,225** | **5,470** | **5,751** | **6,099** |
| ចំណាយចរន្ត | 5,102 | 5,111 | 5,435 | 5,715 | 6,062 |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *4,184* | *4,184* | *4,456* | *4,690* | *4,989* |
| ចំណាយមូលធន | 114 | 114 | 34 | 35 | 36 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *30* | *84* | *34* | *35* | *36* |
| **គ.វិស័យសង្គមកិច្ច** | **8,990** | **9,814** | **9,265** | **10,129** | **11,142** |
| ចំណាយចរន្ត | 7,927 | 8,752 | 8,680 | 9,518 | 10,487 |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *4,028* | *4,028* | *4,227* | *4,506* | *4,788* |
| ចំណាយមូលធន | 1,062 | 1,062 | 585 | 611 | 655 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *130* | *130* | *150* | *165* | *182* |
| **ឃ.វិស័យសេដ្ឋកិច្ច** | **7,046** | **7,050** | **9,987** | **11,553** | **13,682** |
| ចំណាយចរន្ត | 1,582 | 1,586 | 1,631 | 1,709 | 1,792 |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *581* | *581* | *604* | *636* | *669* |
| ចំណាយមូលធន | 5,464 | 5,464 | 8,356 | 9,844 | 11,890 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *545* | *545* | *2,769* | *4,111* | *5,797* |
| **ង.ចំណាយផ្សេងៗ** | **12,273** | **10,559** | **7,339** | **8,910** | **9,074** |
| ចំណាយចរន្ត | 3,387 | 1,673 | 5,808 | 7,323 | 8,041 |
| ចំណាយមូលធន | 8,886 | 8,886 | 1,530 | 1,587 | 1,033 |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *7,026* | *7,026* | *1,530* | *1,587* | *1,033* |
| **1.2 ចំណាយថ្នាក់ក្រោមជាតិ** | **4,062** | **3,902** | **4,234** | **4,654** | **5,256** |

| កំណើនប្រចាំឆ្នាំ | 2023 ច្ប./ 2022 ប. | 2023 ប៉ាន់./ 2022 ប. | 2024 គ្រ. | 2025 គ្រ. | 2026 គ្រ. |
|---|---|---|---|---|---|
| **1. ចំណាយសរុបតាមវិស័យ** | **20.7%** | **19.3%** | **-3.0%** | **12.6%** | **9.9%** |
| **1.1 ចំណាយថ្នាក់ជាតិ** | **22.4%** | **21.4%** | **-3.9%** | **13.0%** | **9.8%** |
| **ក.វិស័យរដ្ឋបាលទូទៅ** | **15.7%** | **37.4%** | **-22.2%** | **9.4%** | **6.9%** |
| ចំណាយចរន្ត | 14.4% | 37.6% | -22.3% | 9.9% | 6.9% |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *7.6%* | *7.6%* | *4.2%* | *3.6%* | *4.3%* |
| ចំណាយមូលធន | 34.0% | 34.0% | -21.9% | 2.6% | 6.3% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | - | - | - | - | - |
| **ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់** | **6.9%** | **7.1%** | **4.7%** | **5.1%** | **6.1%** |
| ចំណាយចរន្ត | 6.8% | 7.0% | 6.3% | 5.2% | 6.1% |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *7.7%* | *7.7%* | *6.5%* | *5.3%* | *6.4%* |
| ចំណាយមូលធន | 9.4% | 9.4% | -69.8% | 3.0% | 3.0% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *32.7%* | *270.2%* | *-59.0%* | *3.0%* | *3.0%* |
| **គ.វិស័យសង្គមកិច្ច** | **10.6%** | **20.7%** | **-5.6%** | **9.3%** | **10.0%** |
| ចំណាយចរន្ត | 10.9% | 22.4% | -0.8% | 9.7% | 10.2% |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *10.5%* | *10.5%* | *4.9%* | *6.6%* | *6.3%* |
| ចំណាយមូលធន | 8.1% | 8.1% | -45.0% | 4.5% | 7.3% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *18.2%* | *18.2%* | *15.4%* | *10.0%* | *10.0%* |
| **ឃ.វិស័យសេដ្ឋកិច្ច** | **18.2%** | **18.3%** | **41.7%** | **15.7%** | **18.4%** |
| ចំណាយចរន្ត | 4.4% | 4.7% | 2.8% | 4.8% | 4.8% |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *1.4%* | *1.4%* | *4.0%* | *5.4%* | *5.2%* |
| ចំណាយមូលធន | 22.9% | 22.9% | 52.9% | 17.8% | 20.8% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *-86.0%* | *-86.0%* | *408.1%* | *48.5%* | *41.0%* |
| **ង.ចំណាយផ្សេងៗ** | **48.5%** | **27.8%** | **-30.5%** | **21.4%** | **1.8%** |
| ចំណាយចរន្ត | 70.0% | -16.0% | 247.1% | 26.1% | 9.8% |
| ចំណាយមូលធន | 41.7% | 41.7% | -82.8% | 3.7% | -34.9% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *63.3%* | *63.3%* | *-78.2%* | *3.7%* | *-34.9%* |
| **1.2 ចំណាយថ្នាក់ក្រោមជាតិ** | **5.8%** | **1.6%** | **8.5%** | **9.9%** | **12.9%** |

| ផលធៀបនៃផ.ស.ស | 2023 ច្ប. | 2023 ប៉ាន់. | 2024 គ្រ. | 2025 គ្រ. | 2026 គ្រ. |
|---|---|---|---|---|---|
| **1.1 ចំណាយថ្នាក់ជាតិ** | **27.98%** | **27.75%** | **24.42%** | **25.19%** | **25.17%** |
| **ក.វិស័យរដ្ឋបាលទូទៅ** | **2.35%** | **2.79%** | **1.99%** | **1.99%** | **1.93%** |
| ចំណាយចរន្ត | 2.17% | 2.61% | 1.86% | 1.86% | 1.81% |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *0.58%* | *0.58%* | *0.56%* | *0.53%* | *0.50%* |
| ចំណាយមូលធន | 0.18% | 0.18% | 0.13% | 0.12% | 0.12% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *0.00%* | *0.00%* | *0.00%* | *0.00%* | *0.00%* |
| **ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់** | **3.99%** | **3.99%** | **3.83%** | **3.67%** | **3.54%** |
| ចំណាយចរន្ត | 3.90% | 3.91% | 3.80% | 3.65% | 3.52% |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *3.20%* | *3.20%* | *3.12%* | *2.99%* | *2.90%* |
| ចំណាយមូលធន | 0.09% | 0.09% | 0.02% | 0.02% | 0.02% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *0.02%* | *0.06%* | *0.02%* | *0.02%* | *0.02%* |
| **គ.វិស័យសង្គមកិច្ច** | **6.87%** | **7.50%** | **6.48%** | **6.47%** | **6.47%** |
| ចំណាយចរន្ត | 6.06% | 6.69% | 6.07% | 6.08% | 6.09% |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *3.08%* | *3.08%* | *2.96%* | *2.88%* | *2.78%* |
| ចំណាយមូលធន | 0.81% | 0.81% | 0.41% | 0.39% | 0.38% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *0.10%* | *0.10%* | *0.10%* | *0.11%* | *0.11%* |
| **ឃ.វិស័យសេដ្ឋកិច្ច** | **5.39%** | **5.39%** | **6.99%** | **7.38%** | **7.95%** |
| ចំណាយចរន្ត | 1.21% | 1.21% | 1.14% | 1.09% | 1.04% |
| *ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក* | *0.44%* | *0.44%* | *0.42%* | *0.41%* | *0.39%* |
| ចំណាយមូលធន | 4.18% | 4.18% | 5.85% | 6.29% | 6.91% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *0.42%* | *0.42%* | *1.94%* | *2.62%* | *3.37%* |
| **ង.ចំណាយផ្សេងៗ** | **9.38%** | **8.07%** | **5.13%** | **5.69%** | **5.27%** |
| ចំណាយចរន្ត | 2.59% | 1.28% | 4.06% | 4.68% | 4.67% |
| ចំណាយមូលធន | 6.79% | 6.79% | 1.07% | 1.01% | 0.60% |
| *ក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេស* | *5.37%* | *5.37%* | *1.07%* | *1.01%* | *0.60%* |
| **1.2 ចំណាយថ្នាក់ក្រោមជាតិ** | **3.11%** | **2.98%** | **2.96%** | **2.97%** | **3.05%** |